# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៥ ខែវិច្ឆិកា លេខ ១១

ព.ស. ២៤៩៦ – គ.ស. ១៩៥៣

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា — បញ្ជីរឿង — ទំព័រ


— នាថករណធម៌ .............. ព្រះមហា យ៉ត–ទ្រលន់...... ៨០៣
— យក្សប្រេតមានមែនឬទេ ......... លោក ប៊ូ - ប៊ូ .......... ៨២៣


ផ្នែកអក្សរសាស្ត្រ


— ការបណ្តុះនិស្ស័យ (តមក)...... ព្រះមហាឧត្តមវិជ្ជា ប៉ឹង - ប៉ម.... ៨៣០
— រឿងសាមកុក (តមក)...... ឧកញ៉ា នូ - កន........... ៨៣៥
— រឿងអារ័ក្សថ្លែងរឿងម្តៃប្រាំ (តមក)... លោក រ៉ាយ - ប៊ុក .......... ៨៣៩
— រឿងបិញ្ចៀនទិព្យ (តមក).......... អ្នកស្រសារយ៉ាន .......... ៨៤៩
— សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ
មះយាបរពើពាក្យ វរ្ម័ន ........ លោកបាប- ពិន .......... ៨៥៣


កំណត់និងប្រវត្តិការណ៍


— ពិធីប្រឡងសិស្សសាលាបាលីរងនៅដែន .
កូសាំងស៊ីន ភាគខាងត្បូង ........ ព្រះញាណកោសល ញាណ–ឈិន ៨៦៦


មួយឆ្នាំមាន ១២ សៀវភៅ — តំឡៃជាវ ១៩២រ. ០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


### PARTIE RELIGIEUSE

| | | Page |
|---|---|---|
| — Nathakaranadharma . . . . | *brah maha* YAT-TRALON. . . | 803 |
| — Les Démons infernaux . . . | M. BOU-PO . . . . . . . . . . | 823 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| — Education morale (suite) . . | Brah Maha PEUNG-PAM . . . | 830 |
| — Histoire de SAMKOK (suite) . . | Oknha NOU-KAN . . . . . . . | 835 |
| — Les vingt cinq récits du Mauvais Génie (suite) . . . . . . . . . . | M. RAY-BUC . . . . . . . . | 839 |
| — La bague magique (suite) . . . | Mme SARIS-YANN . . . . . . . . . . | 849 |
| — Activité de la Commission des Mœurs et Coutumes (Varman) | M. CHAP-PIN . . . . . . . . . . . . | 853 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| — Examen de sortie des Ecoles Elementaires de Pali en cochinchine . . . . . . . . . . | Ven. NHEAN-CHHŒUN . . . | 866 |


Prix d'abonnement annuel (comprenant 12 numéros): 192$00

# នាថករណធម៌

## ព្រះមហា យ៉ត-ទ្រលង់ វត្តលង្កា ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុប្រទេសកម្ពុជា កាលពីថ្ងៃ១៥កើត ខែជេស្ឋ ឆ្នាំឆ្លូវឯកស័ក
ព.ស. ២៤៩ (១១-៦-៤៩) ។

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*កិរិយានមស្ការ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយសេចក្តីគោរព) ។*

*វេលានេះ អាត្មាភាពសូមសំដែងអំពីនាថករណធម៌ គឺធម៌ជាគ្រឿងធ្វើនូវទីពឹង ជូនជាសណ្តាប់នៃសាធុសប្បុរសទាំងឡាយ ។ ឯនាថករណធម៌នោះ ១០ យ៉ាង គឺ:*

១– សីល *រក្សាកាយវាចាឲ្យរាបសា,*

២– ពាហុសច្ចៈ *ភាពជាបុគ្គលបានស្តាប់ បានរៀនពុទ្ធវចនៈច្រើន,*

៣– កល្យាណមិត្តតា *ភាពជាបុគ្គលមានមិត្តសំឡាញ់ល្អ,*

៤– សោវចស្សតា *ភាពជាបុគ្គលងាយប្រដៅ,*

៥— កឹករណីយេសុ ទក្ខតា ភាពជាបុគ្គលមានសេចក្តីខ្នះខ្នែង ក្នុងកិច្ចធុរៈរបស់មិត្តអ្នកប្រព្រឹត្តធម៌ជាមួយគ្នា,

៦— ធម្មកាមតា ភាពជាបុគ្គលស្រឡាញ់ធម៌ដែលប្រពៃ,

៧— វីរិយៈ ការព្យាយាមលះអំពើអាក្រក់ ហើយប្រព្រឹត្តតែអំពើល្អ,

៨— សន្តោសៈ ការត្រេកអរចំពោះវត្ថុដែលជារបស់ខ្លួនតាមមានតាមបាន,

៩— សតិ ការរលឹកឃើញកិច្ចការដែលធ្វើហើយនឹងពាក្យសំដីដែលនិយាយហើយ,

១០— បញ្ញា ការដឹងច្បាស់ក្នុងកងសង្ខារតាមសភាពពិតមែន ៗ

ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ នឹងនៅតែម្នាក់ឯងមិនបាន, ដូចក្មេងៗ ដែលទើបនឹងកើតមក គោងអាស្រ័យនឹងចាស់ៗ មានមាតាបិតាជាដើម ឲ្យជួយចិញ្ចឹមជីវិតផងទើបរស់, កាលបើធំបន្តិចឡើងហើយ ក៏នៅតែអាស្រ័យនឹងអ្នកដទៃទៀតដោយបើជាប់ ដូចអាស្រ័យនឹងគ្រូអាចារ្យឲ្យជួយបង្ហាត់បង្ហាញវិជ្ជាចំណេះ នឹងសេចក្តីប្រព្រឹត្តជាដើម,លុះដល់ពេញកំឡោះក្រមុំ ដែលជាពេលត្រូវរកទ្រព្យសម្រាប់ចិញ្ចឹមជីវិតនោះសោត ក៏គោងពឹងពាក់អ្នកនេះខ្លះ អ្នកនោះខ្លះ

បានសេចក្ដីថា មនុស្សដែលកើតមកក្នុងលោក គោរពនឹងអ្នកដទៃ ដើម្បីប្រយោជន៍លោកិយសម្បត្តិទើបបាន, តែនឹងពឹងដើម្បីលោកុត្តរសម្បត្តិ គឺមគ្គផលព្រះនិព្វានផង នោះមិនបានឡើយ ។

សេចក្ដីនេះសមដូចពុទ្ធភាសិតក្នុងព្រះធម្មបទថា:

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ

សេចក្ដីថា ខ្លួនឯងជាទីពឹងរបស់ខ្លួន អ្នកដទៃដូចម្ដេចឡើយនឹងជាទីពឹងបាន ព្រោះបុគ្គលដែលមានខ្លួនហ្វឹកហ្វឺនល្អហើយ តែងបាននូវទីពឹងដែលគេរកបានដោយកម្រ ។

សម្ដេចព្រះទសពលញាណបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់ទេសនាប្រៀនប្រដៅពុទ្ធបរិស័ទឲ្យខំប្រឹងធ្វើសេចក្ដីប្រតិបត្តិ យកសម្បត្តិសួគ៌និងសម្បត្តិព្រះនិព្វាន ចំពោះខ្លួនឯងពល់ ៗ គ្នា មិនឲ្យអាងអ្នកដទៃក្រៅអំពីខ្លួនឯងឡើយ ព្រោះបណ្ដាមនុស្សដែលនឹងបានទៅកើតស្ថានសួគ៌ នឹងធ្វើមគ្គផលឲ្យកើតមានជាក់ច្បាស់ប្រាកដឡើងបាននោះ ក៏ព្រោះតែគេខំប្រឹងកសាងសន្សំបុណ្យកុសល ដម្កល់ក្នុងខ្លួនចំពោះ ៗ ខ្លួនរបស់គេឲ្យសម្បូណ៌ឡើង, មិនមែនបានមកអំពីអ្នកដទៃឡើយ ។ បើជនណាបានហ្វឹកហ្វឺនទូន្មានខ្លួនឲ្យល្អប្រពៃ គឺឲ្យមានកាយវាចាចិត្តស្ងប់រម្ងាប់ពបសាឥតមានពុតក្បុតហើយ ជននោះឯងតែងបាននូវទីពឹងដ៏ខ្ពង់ខ្ពស់ គឺបាន

សំរេចព្រះអរហត្តផល ដែលជាគុណវិសេសយ៉ាងខ្ពស់បំផុតក្នុងព្រះពុទ្ធ-សាសនាដែលគេរកបានដោយកម្រក្រៃពេក ៗ

ត្រង់ពាក្យថា: "មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ សុទ្ធតែត្រូវពឹងពាក់គ្នាទៅវិញទៅមក ទើបអាចប្រព្រឹត្តទៅបាន" នោះក៏ពិតមែនហើយ ប៉ុន្តែពឹងគ្នាបានតែត្រឹមលោកិយសម្បត្តិប៉ុណ្ណោះ មិនពឹងឲ្យទៅដល់លោកុត្តរសម្បត្តិ គឺមគ្គផលព្រះនិព្វានផងនោះមិនបានទេ, បំណែកខាងលោកុត្តរសម្បត្តិនោះត្រូវតែរកបំពោះខ្លួនទើបបាន តែបើទុកជាដូច្នោះ ក៏គង់តែអាស្រ័យគ្រូអាចារ្យមានព្រះសម្មាសម្ពុទ្ធជាដើម ឲ្យទ្រង់សំដែងណែនាំពន្យល់ជាមុនដែរ វៀរលែងតែព្រះសម្មាសម្ពុទ្ធ ១ ព្រះអង្គប៉ុណ្ណោះ ទើបទ្រង់ត្រាស់ដឹងឯងហើយទ្រង់ណែនាំអ្នកដទៃឲ្យត្រាស់ដឹងផង, ប៉ុន្តែការណែនាំនោះ ក៏បានបំពោះតែនរណាដែលមានវាសនាបារមី មិនមែនបានទាំងឥតវាសនាផងទេ, សូម្បីតែសម្តេចព្រះបរមគ្រូជាម្ចាស់ដែលប្រាកដច្បាស់ថាជាទីពឹងពំនាក់របស់សត្វលោក មិនមាននរ-ណាជាងព្រះអង្គនោះ ក៏ទ្រង់ជាទីពឹងបំពោះតែសត្វណាដែលមានគតិគួរឲ្យព្រះអង្គណែនាំបានប៉ុណ្ណោះ, ព្រះអង្គមិនណែនាំបានឲ្យទៅទាំងមនុស្សដែលជាអភព្វបុគ្គលនោះក៏ទេ ៗ សេចក្តីនេះគួរឃើញដូចជាទេវទត្តដែលជាអភព្វបុគ្គលជាដើម, សូម្បីចូលមកបួសក្នុងព្រះពុទ្ធសាសនានឹងគេដែរ តែជាមនុស្សប្រព្រឹត្តអាក្រក់ច្រើនពេកណាស់, ព្រះសម្មាសម្ពុទ្ធជា

ម្ចាស់ក៏មិនអាចធ្វើមនុស្សមានសភាពដូច្នោះ ឲ្យសំរេចមគ្គផលដូចជាបុគ្គលឯទៀតបានទេ. ព្រោះមិនមានធម៌ជាទីពឹងចំពោះខ្លួនឯងផង លុះតែនរណាដែលជាបុគ្គលមានក័ព្ធធ្លាប់ធ្វើបុណ្យកុសលដម្កល់ទុកមកពីមុនៗដែលហៅថា ពន្ធនេយ្យសត្វ ជាផៅពង្សគួរឲ្យព្រះអង្គទូន្មានបាន, ទើបអាចជួយអប់រំនិស្ស័យនៃជនមានសភាពដូច្នោះ ឲ្យសំរេចមគ្គផលសមគួរតាមឧបនិស្ស័យរបស់គេ ។

ចំណែកឯសម្តេចព្រះអនាវរណញ្ញាណ ដែលទ្រង់ប្រទានព្រះធម្មទេសនាក៏គ្រាន់តែប្រៀបដូចអ្នកបង្ហាញផ្លូវប៉ុណ្ណោះ ត្រង់ដើរតាមគន្លងនោះកើតឬទេ ក៏ស្រេចនៅៈលើអ្នកដើរ សេចក្តីនេះសមដូចជាពុទ្ធភាសិតគង់ព្រះធម្មបទថា:

តុម្ហេហិ កិច្ចំ អាតប្បំ អក្ខាតារោ តថាគតា
បដិបន្នា បមោក្ខន្តិ ឈាយិនោ មារពន្ធនា

សេចក្តីថា: អ្នកទាំងឡាយត្រូវធ្វើសេចក្តីព្យាយាមចំពោះខ្លួនឯងចុះ ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់ផ្លូវឲ្យទេ, បើពួកជនណាបានដើរគឺបានរំពឹងពិនិត្យធ្វើតាមហើយ ជនទាំងនោះមុខជានឹងបានរួចចាកចំណងគឺកិលេសមារមិនខានឡើយ ។

សេចក្តីប្រតិបត្តិដែលជាហេតុឲ្យដល់ទីរលត់ទុក្ខប្រៀបដូចជាផ្លូវ, ជនដែលជាអ្នកប្រតិបត្តិប្រៀបដូចជាអ្នកដំណើរ, ព្រះពុទ្ធជាម្ចាស់ដែលត្រាស់

ទេសនាប្រដៅសត្វប្រៀបដូចជាអ្នកបង្ហាញផ្លូវកន្លែងលោកនេះ, កាលបានបង្ហាញអ្នកណាហើយ បើអ្នកនោះគេមិនដើរ អ្នកបង្ហាញនោះនឹងដើរជំនួសគេក៏ទេដែរ ត្រង់ដើរកើតឬមិនកើតនោះក៏ស្រេចនៅលើអ្នកដំណើរ បើអ្នកដំណើរនោះគេដើរទៅ ខ្លួនគេទើបបានដល់ទីដែលគេប្រាថ្នា បើគេមិនដើរក៏មិនបានដល់ ។ ព្រោះហេតុនេះហើយ បានជាសម្តេចព្រះមុនិន្ទសាស្តាចារ្យជាម្ចាស់ត្រាស់ទេសនាថា: ខ្លួនឯងជាទីពឹងចំពោះខ្លួន អ្នកដទៃដូចម្តេចឡើយ ទឹងជាទីពឹងបាន ។ បានសេចក្តីថា: ខ្លួនរបស់ខ្លួនត្រូវប្រឹងជួយខ្លួនឯងផង, ទើបអ្នកឯទៀតគេជួយបាន បើខ្លួនឯងមិនប្រឹងផងទេ, អាងតែគេ គេក៏ជួយមិនកើត ។ មួយទៀតគួរឃើញដូចអ្នកដែលឡើងដើមឈើខ្ពស់ៗ មានដើមត្នោតជាដើម ហើយមិនរបូតធ្លាក់នោះក៏ព្រោះអាស្រ័យកម្លាំងខ្លួនឯងផ្សងផងទើបឡើងរួច ទឹងបណ្តោយថាស្រេចនៅលើដើមឈើទាំងអស់តែម្តងក៏មិនបាន ។

ហេតុនេះ ពុទ្ធបរិសទ្យដែលប្រាថ្នាចង់បានសេចក្តីសុខ ក្នុងជាតិនេះនឹងជាតិខាងមុខនឹងសេចក្តីសុខយ៉ាងខ្ពស់បំផុតគឺព្រះនិព្វាននោះ ត្រូវតែខំកសាងសន្សំបុណ្យកុសលចំពោះៗខ្លួន ព្រោះសម្បត្តិសួគ៌នឹងសម្បត្តិព្រះនិព្វានដែលបុគ្គលនឹងបាន ក៏សុទ្ធតែបានអំពីសេចក្តីប្រតិបត្តិរបស់ខ្លួនឯងទាំងអស់ មិនដែលបានមកអំពីអ្នកដទៃឲ្យទេ ។ ម្យ៉ាងទៀត សាធុសប្បុរសទាំងឡាយដែលជាអ្នកស្រឡាញ់ខ្លួន ត្រូវមានធម៌ជាទីពឹង

ចំពោះខ្លួនរាល់ៗខ្លួន ព្រោះអ្នកដែលមានធម៌ជាទីពឹងចំពោះខ្លួន តែងនៅជាសុខគ្មានទុក្ខលំបាកឡើយ ។ សេចក្ដីនេះសមដូចជាពុទ្ធភាសិតដែលសម្ដេចព្រះភគវន្តមុនីបរមគ្រូជាម្ចាស់ត្រាស់ទេសនា ទុកក្នុងនាថករណធម្មសូត្រ គម្ពីរទីឃនិកាយ បាដិកវគ្គថា: សនាថា ភិក្ខវេ វិហរថ មា អនាថា ទុក្ខំ ភិក្ខវេ អនាថោ វិហរតិ ដូច្នេះជាដើម ។

សេចក្ដីថា: ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរជាបុគ្គលមានទីពឹងសិនហើយសមនៅចុះ កុំជាបុគ្គលឥតទីពឹងឡើយ ព្រោះបុគ្គលឥតទីពឹងតែងនៅជាទុក្ខ ។

នាថករណធម៌ គឺធម៌ធ្វើទីពឹងរបស់អ្នកប្រតិបត្តិធម៌នេះ ដំបូងឡើយសម្ដេចព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទេសនា ដើម្បីជាវត្តប្រតិបត្តិរបស់អ្នកបួសទេ, ព្រោះបណ្ដាពុទ្ធបរិសទ្យទាំង ៤ ពួកនោះ មានពួកភិក្ខុនេះឯងជាប្រមុខរបស់បរិសទ្យទាំងអស់ លោកច្រើនបានស្ដាប់ធម៌មុនគេ តែបើទុកជាដូច្នោះ គ្រហស្ថនឹងអនុលោមប្រតិបត្តិតាមផងបានឥតមានទាស់ទេ សឹងបានសម្រេចប្រយោជន៍គ្រប់គ្នា ។ វេលានេះអាត្មាភាពនឹងពណ៌នា ឲ្យសមគួរដល់សេចក្ដីប្រតិបត្តិទាំងបព្វជិត និងគ្រហស្ថដូចតទៅនេះ ៖

១ – ការរក្សាកាយវាចា ឲ្យរាបសា លោកហៅថា សីលំ សីលនេះបើសំដែងដោយបរិយាយ បានដល់សិក្ខាបទដែលបុគ្គល ៗ មានទាន

ហើយ មានវិរតិចេតនាវៀរចាកបាបដោយកាយនឹងវាចា មានវៀរចាកបញ្ចវេរកជាដើម ។

សីលនេះ ជាធម៌ធ្វើទីពឹងរបស់អ្នកដែលរក្សា គឺអាចការពារនូវអំពើខូចកាចអាក្រក់តាមកាយនឹងវាចាមិនឲ្យកើតឡើងបាន ។ បុគ្គលដែលនឹងរក្សាសីលបរិសុទ្ធ តែងបានសេចក្ដីសុខឃើញទាន់ភ្នែក គឺរួចចាកទោសដែលមានទុក្ខឹងបច្ចុប្បន្នមានរាជអាជ្ញាជាដើម, តាំងបានជាទីគោរពរាប់អានស្រឡាញ់របស់ជនទាំងពួង ហើយនឹងជាមនុស្សក្លៀវក្លាក្នុងកណ្ដាលប្រជុំបរិសទ្យ ។ ម្យ៉ាងទៀតសីលនេះ តែងបានជាបច្ច័យនៃការប្រតិបត្តិធម៌ជាន់ខ្ពស់ ៗ ទៅដោយលំដាប់ផង ។ ធម្មតាបុគ្គលដែលប្រព្រឹត្តតាមពាក្យប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដរាបដល់បានសំរេចមគ្គនឹងផលយ៉ាងខ្ពស់ គឺរហូតដល់លះកិលេសឲ្យអស់ទៅ ដែលហៅថាព្រះអរហន្តស្រេចបាននោះ ក៏ព្រោះតែប្រព្រឹត្តធម៌ជាន់ទាប ៗ ជាដំបូងសិន ទើបសំរេចទៅបាន គួរឃើញដូចអ្នកឡើងទៅលើទីខ្ពស់ ៗ ក៏ព្រោះតែអាស្រ័យនឹងគ្រឿងមានជណ្ដើរជាដើម តាំងពីជាន់ទាប ៗ ឡើងទៅជាថ្នាក់ ៗ ទើបទៅដល់ទីដែលខ្លួនប្រាថ្នាបាន បើមិនដូច្នោះទេ ក៏ទៅមិនដល់ឡើយ សេចក្ដីនេះមានឧបមាយ៉ាងណាមិញ ការដែលប្រតិបត្តិធម៌វិន័យក្នុងព្រះពុទ្ធសាសនាក៏មានឧបមេយ្យយ៉ាងនោះដែរ គឺសីលនេះឯងតែងជាទីដម្កល់នៃការកុសលជាន់ដំបូងសំរាប់អ្នកដែលប្រតិបត្តិ ត្រូវ

បំពេញឲ្យគ្រប់គ្រាន់ជាមុនសិន, ហើយសិមឈានឡើងទៅរកសមាធិ និងបញ្ញាជាលំដាប់ៗទៅ ដំកបដល់ធ្វើខ្លួនឲ្យដល់នូវវិមុត្តិ, គឺព្រះនិព្វានបាន ។ ព្រោះហេតុនោះ សីលទើបលោកចាត់ជាធម៌ធ្វើទីពឹងខាងដើមបំផុត ។

២ - ឯការដែលបុគ្គលនឹងរក្សាសីលនោះបាន, ក៏គោងអាស្រ័យនឹងការស្ដាប់ការរៀនធម៌ឲ្យចេះដឹងស្គាល់ខុសត្រូវល្អអាក្រក់ ឲ្យកាស់ក្រែលជាមុនសិន ទើបអាចប្រព្រឹត្តទៅបាន ដោយហេតុនេះ បានជាសម្ដេចព្រះអនាវរណញ្ញាណជាម្ចាស់ទ្រង់លើកយក ពាហុសច្ចៈ (ភាពជាបុគ្គលបានស្ដាប់ បានរៀនទន្ទេញពុទ្ធវចនៈចេះចាំច្រើនឡើង) សំដែងថាជាធម៌ធ្វើទីពឹង គំរប់ពីរ ។ ឯគុណធម៌ពាហុសច្ចៈនេះបើមានកងសន្ដាននៃបុគ្គលណាហើយ តែងធ្វើបុគ្គលនោះឲ្យជាមនុស្សចេះដឹងនឹងយល់ចិត្តហេតុផលដោយច្បាស់ណាស់, ជាគ្រឿងដឹកនាំឲ្យប្រព្រឹត្តត្រឹមត្រូវ, នឹងនាំឲ្យបានសេចក្ដីសុខទាំងជាតិនេះនឹងជាតិខាងមុខសមតាមប្រាថ្នា, មិនតែប៉ុណ្ណោះសោត តែងនាំឲ្យបានជាទីពុំនាក់អាស្រ័យភិក្ខុសាមណេរនឹងឧបាសកឧបាសិកាថែមទៀតផង ។ រឿងនេះគួរឃើញដូចព្រះអានន្ទត្ថេរដែលជាអគ្គពហុស្សុតលោកបានធ្វើបឋមសង្គាយនារៀបរៀងព្រះត្រៃបិដកពុទ្ធវចនៈ ធ្វើឲ្យព្រះពុទ្ធសាសនាផ្សាយទូលាយឡើងទុកឲ្យជាប្រយោជន៍ដល់ពុទ្ធបរិសទ្យ ជនដែលកើតមកខាងក្រោយ ក៏បាន

នាំគ្នារៀនសូត្រច្រើនឆ្លងចូលចិត្តប្រតិបត្តិតាមដោយសារលោក ដរាបដល់មកសព្វថ្ងៃនេះ ទាំងនេះក៏ដោយអំណាចលោកបានរៀនបានស្ដាប់ពុទ្ធវចនៈច្រើនជាដើមហេតុ ៗ ព្រោះហេតុដូចពោលមកនេះ ពាហុសច្ចៈ (ភាពជាបុគ្គលបានស្ដាប់បានរៀនពុទ្ធវចនៈច្រើន) នេះឯងទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ពីរ ៗ

៣- ឯការដែលស្ដាប់និងរៀនពុទ្ធវចនៈឱ្យបានច្រើននោះ សោតក៏អាស្រ័យដោយការចូលទៅគប់ប្រសប់ និងកល្យាណជនជាអ្នកប្រាជ្ញ ឱ្យលោកបង្ហាត់បង្ហាញផ្លូវខុសនិងត្រូវជាគោលចារិកសិន ទើបសម្រេចទៅបាន ព្រោះហេតុដូច្នេះបានជាព្រះសក្យមុនីបរមគ្រូជាម្ចាស់ទ្រង់លើកយក កល្យាណមិត្តតា (ភាពជាបុគ្គលមានមិត្តសំឡាញ់ល្អ) ឡើងសំដែងថាជាធម៌ធ្វើទីពឹង គំរប់បី ៗ ឯគុណធម៌នេះជាគ្រឿងសំខាន់ ក្នុងការយកគយោងសណ្ដានបុគ្គលឱ្យប្រព្រឹត្តល្អត្រឹមត្រូវ ព្រោះតាមធម្មតាមិត្តសំឡាញ់រមែងដឹកនាំអ្នកដែលគប់រកឱ្យប្រព្រឹត្តល្អនិងប្រព្រឹត្តអាក្រក់ទៅតាមគ្នាដោយឆាប់រហ័ស គប់និងពាល ៗ តែងនាំឱ្យធ្វើទុច្ចរិត គប់និងបណ្ឌិត ៗ តែងនាំឱ្យធ្វើត្រឹមត្រូវល្អ ដូចសំពត់សតែងជិតពណ៌ទៅតាមទឹកជ្រលក់ ទោះបីសំពត់នោះស្អាតដូចម្ដេចក៏ដោយ ឱ្យតែមកអាស្រ័យនិងទឹកជ្រលក់ ៗ ក៏តែងនាំឱ្យផ្លាស់សម្បុរទៅតាមទឹកជ្រលក់នោះ ៗ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ការដែលគប់និងមិត្តសំ-

ឡាញ់ក៏ដូច្នោះដែរ, នោះបើនរណាប្រព្រឹត្តល្អមកពីដើមក៏ដោយ ឲ្យតែមកគប់ប្រសប់នឹងពាលរឿយ ៗ ក៏មុខជានឹងក្លាយនិស្ស័យល្អនោះបាត់ទៅត្រឡប់កើតនិស្ស័យអាក្រក់ឡើងជាថ្មី ៗ សេចក្តីនេះ គួរឃើញដូចរឿងអជាតសត្តុរាជកុមារ ព្រោះតែយកទេវទត្តជាមិត្ត បានជាផ្តាច់ជីវិតព្រះបាទពិម្ពិសារជាព្រះបិតា ។ ហេតុដូច្នេះ បានជាសម្តេចព្រះលោកុត្ត-មាចារ្យជាម្ចាស់ ត្រាស់ទេសនាប្រដៅប្រជុំជនឲ្យលះបង់ការសេពគប់នឹងជនពាល ឲ្យស្និទ្ធស្នាលតែនឹងជនជាបណ្ឌិត ព្រោះបណ្ឌិតនោះបើនរណាគប់រកហើយ តែងធ្វើអ្នកនោះឲ្យសំរេចប្រយោជន៍ទាំងឥធលោកនឹងបរលោក ហើយនឹងប្រយោជន៍ដ៏ប្រសើរបំផុតគឺព្រះនិព្វាន ។ ព្រោះហេតុដូច្នេះ កល្យាណមិត្តតា (ភាពជាបុគ្គលមានមិត្តសំឡាញ់ល្អ) ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៣ ។

៤ – ឯការដែលគប់ប្រសប់នឹងអ្នកប្រាជ្ញនោះ លោករាប់ថាជាឫសគល់នៃសេចក្តីប្រព្រឹត្តល្អក្រៃពេក ក៏ពិតមែនហើយ ប៉ុន្តែបើគ្រាន់តែគប់ប្រសប់ប៉ុណ្ណោះមិនតាំងចិត្តស្តាប់ពាក្យប្រដៅនឹងមិនប្រតិបត្តិតាមទេ, ក៏មិនទាន់ជាប្រយោជន៍ប៉ុន្មាន ហេតុនេះ បានជាសម្តេចព្រះជិនស្រីម្ចាស់ទ្រង់លើកយក សោវចស្សតា (ភាពជាបុគ្គលងាយប្រដៅ) ទៀងសំដែងថាជាធម៌ធ្វើទីពឹង គំរប់បួន ។ ឯគុណធម៌នេះ បើមានក្នុងសន្តានរបស់បុគ្គលណាហើយ តែងធ្វើបុគ្គលនោះឲ្យជាទីជ្រះថ្លា តាំង

ជាទីគប់អានដល់អ្នកប្រដៅ ហើយទឹងជាផ្សព្វប្រឡាយជាទីហូរមកនូវគុណធម៌ដទៃទៀតច្រើនយ៉ាងផង, ព្រោះគុណធម៌ឯទៀតៗ ដែលទឹងកើតឡើងបាននោះ ក៏អាស្រ័យទឹងការស្តាប់ហើយប្រព្រឹត្តតាមនេះជាទីតាំង តែបើស្តាប់ហើយមិនបានត្រិះរិះឲ្យចូលចិត្តទឹងមិនប្រព្រឹត្តតាមទេ, ក៏មិនទាន់គប់ថាវិសេសជាងគេដែលមិនបានស្តាប់ប៉ុន្មាន, ព្រោះមិនបានសំរេចប្រយោជន៍យ៉ាងណាឡើយ, មានគួរនាដូចវែកដែលមិនដឹងរស់សម្ល ៗ ព្រោះហេតុនោះ កាលបើបានជួបប្រទះនឹងអ្នកប្រាជ្ញ ហើយបានស្តាប់ពាក្យប្រដៅរបស់លោក ត្រូវកុំមានទិដ្ឋិមានះឡើយ, គួរត្រិះរិះឲ្យដឹងច្បាស់ឲ្យយល់ស៊ប់ក្នុងចិត្ត ហើយខំប្រតិបត្តិឲ្យដល់កំរិតរបស់ធម៌នោះ ៗ ចុះ ទើបទឹងបានសម្រេចប្រយោជន៍អំពីការសេពគប់ គឺមុខជាបានបេះដឹងទឹងបានប្រព្រឹត្តល្អរៀបរយដោយឆាប់ក្លាម ៗ មានគួរនាដូចអណ្តាតដែលឆាប់ដឹងរសសម្ល ៗ ព្រោះហេតុនេះ **សោវចស្សតា** (ភាពជាបុគ្គលងាយប្រដៅ) ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៤ ៗ

៥ - ឯការដែលគប់រកគ្នាជាមិត្តសំឡាញ់នោះសោត, អ្នកទាំងពីរខាងត្រូវមានគុណប្រយោជន៍អ្វីមួយ តិចឬច្រើន ឲ្យជាគ្រឿងភ្ជាប់ចិត្តគ្នានឹងគ្នា ទើបយកជាគ្នាបាន, បើមិនដូច្នោះទេ ក៏មិនផ្សេងពីគេដែលមិនមែនជាមិត្តប៉ុន្មាន, ឬគប់ប្រសប់គ្នាមិនជាប់បានយូរ ដោយហេតុដូចពោលមកនេះហើយ បានជាសម្តេចព្រះទីបទុត្តមាចារ្យជាម្ចាស់ទ្រង់លើក

យក កិំករណីយេសុ ទក្ខតា (ភាពជាអ្នកជួយខ្នះខ្នែងក្នុងកិច្ចធុរៈ របស់មិត្តអ្នកប្រព្រឹត្តធម៌ជាមួយគ្នា) ទ្រង់សំដែងថាជាធម៌ធ្វើទីពឹង គំរប់ ៦ ព្រោះគុណធម៌នេះឯង តែងជាគ្រឿងទាញចិត្តរបស់អ្នកដែលបានទទួលឧបការៈឲ្យមកជាមិត្តសំឡាញ់បាន មិនតែប៉ុណ្ណោះឡើយ តែងធ្វើបុគ្គលដែលជាមិត្តសំឡាញ់នឹងគ្នាស្រាប់មកហើយ ឲ្យរឹងរឹតតែជិតស្និទ្ធនឹងគ្នាថែមទៀតផង ។ ម្យ៉ាងទៀត បុគ្គលដែលនឹងតាំងខ្លួនឲ្យជាមនុស្សស្តុកស្តម្ភមាំមួនបាននោះ ព្រោះតែកម្លាំងរបស់ខ្លួនម្នាក់ឯងអាចធ្វើបានគ្រប់យ៉ាងក៏ទេ លុះតែអាស្រ័យកម្លាំងរបស់មិត្តសំឡាញ់ច្រើនអ្នកផង ទើបតាំងបាន ប៉ុន្តែដែលអ្នកដទៃគេនឹងមកជួយជាកម្លាំងជូននោះ ក៏ព្រោះតែខ្លួនធ្លាប់ជួយគេដែរ ។ ដោយហេតុនេះឯង កិំករណីយេសុ ទក្ខតា (ភាពជាអ្នកចំប្រឹងយកចិត្តទុកដាក់ជួយធ្វើកិច្ចធុរៈ របស់មិត្តអ្នកប្រព្រឹត្តធម៌ជាមួយគ្នា) ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៥ ។

៦– ឯការដែលបុគ្គលនឹងធ្វើសេចក្តីល្អដូចពណ៌នាមកហើយ ឲ្យគ្រប់ទាំងអស់ ឬយ៉ាងណាម្យ៉ាងនោះ ក៏លុះតែមានសេចក្តីស្រឡាញ់នូវការល្អនោះៗ ឲ្យណាស់ទើបធ្វើបាន ។ ហេតុដូច្នេះ បានជាសម្តេចព្រះសយម្ភូញាណជាម្ចាស់ ទ្រង់លើកយក ធម្មកាមតា (ភាពជាបុគ្គលស្រឡាញ់ធម៌ដែលប្រពៃ) ទ្រង់សំដែងថាជាធម៌ធ្វើទីពឹងជាគំរប់ ៦ ។ ឯគុណធម៌នេះ ជាគ្រឿងជួយទំនុកបំរុងឲ្យបុគ្គលមានកម្លាំង

ប្រព្រឹត្តធម៌ ទើបលោកចាត់ជាឥទ្ធិបាទធម៌ គឺធម៌នាំឲ្យសម្រេចប្រយោជន៍តាមបំណងប្រការមួយ ៗ សេចក្តីនេះ គួរឃើញដូចបុគ្គលដែលនឹងប្រកបកិច្ចការណាមួយ បើប្រសិនជាមិនបណ្តុះចិត្តឲ្យស្រឡាញ់កិច្ចនោះៗជាមុនទេ សេចក្តីប្រឹងប្រែងក្នុងការប្រកបកិច្ចនោះ ៗ ក៏នឹងធូរថយចុះមិនពេញកម្លាំង កុំថាដល់កិច្ចធំ ៗ ឡើយ សូម្បីកិច្ចតូច ៗ ដូចគ្រាន់តែនិយាយសន្ទនាប្រស្រ័យនឹងគ្នាជាដើម ដូនកាលអ្នកស្តាប់មិនគាប់ចិត្តនឹងពាក្យសំដីរបស់អ្នកនិយាយ ក៏នាំឲ្យខូចប្រយោជន៍ក្នុងការសន្ទនាប្រស្រ័យនោះមិនខាន, អម្បាលការបន្តិចបន្តួចត្រឹមប៉ុណ្ណោះម្តេចមិនសម្រេចទៅហើយ ចំណង់បើដល់ទៅការធំ ៗ ដូចយ៉ាងការប្រតិបត្តិធម៌វិន័យដើម្បីធ្វើខ្លួនឲ្យដល់នូវទីរំលត់ទុក្ខគឺព្រះនិព្វាននោះទៀត. បើមិនបណ្តុះសេចក្តីស្រឡាញ់ឲ្យច្រើនទេ ធ្វើម្តេចនឹងកើត ៗ ព្រោះហេតុដូចសំដែងមកនេះ ធម្មកាមតា (ភាពជាបុគ្គលមានសេចក្តីស្រឡាញ់ពេញចិត្តចំពោះធម៌ល្អ) ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៦ ។

៧– បើមានសេចក្តីស្រឡាញ់ពេញចិត្តណាស់ដែរ ប៉ុន្តែមិនបានចុះដៃធ្វើឬគ្រាន់តែធ្វើ ៗ តែមិនខំប្រឹងខ្នះខ្នែងឲ្យមែនទែនទេ កិច្ចការនោះ ៗ ក៏មិនបានសម្រេចឡើយ ព្រោះហេតុនេះហើយ បានជាសម្តេចព្រះទសពលញាណបរមគ្រូជាម្ចាស់ទ្រង់លើកយក វីរិយៈ (សេចក្តីប្រឹងប្រែង) ឡើងសំដែងថា ជាធម៌ធ្វើទីពឹង គំរប់ ៧ ។

ឯគុណធម៌នេះ ជាធម៌សំខាន់បំផុតខាងឯជួយគាំទ្រចិត្តឲ្យមានកម្លាំងក្លាហានមិនឲ្យលះបង់ការងាររបស់ខ្លួនដែលត្រូវធ្វើ ជាហេតុនាំឲ្យសម្រេចប្រយោជន៍ដូចសេចក្ដីប៉ុនប៉ង សេចក្ដីនេះយ៉ាងណាមិញ ការដែលប្រតិបត្តិធម៌វិន័យក្នុងព្រះពុទ្ធសាសនាក៏យ៉ាងនោះដែរ, គឺអាស្រ័យនឹងសេចក្ដីព្យាយាមទំប្រឹងលះបង់អកុសលចោលចេញ ហើយចម្រើនកុសលឲ្យកើតកើនឡើង ទើបអាចរំដោះខ្លួនឲ្យផុតស្រឡះអំពីទុក្ខបានសម្រេចសេចក្ដីសុខតាមប្រាថ្នា ។ សេចក្ដីនេះ សមដូចពុទ្ធភាសិតថា វីរិយេន ទុក្ខមច្ចេតិ " បុគ្គលតែងកន្លងទុក្ខបានដោយសារសេចក្ដីព្យាយាម " ។ ព្រោះហេតុនេះ វីរិយ: ( សេចក្ដីព្យាយាមលះបង់អំពើអាក្រក់ហើយប្រព្រឹត្តតែអំពើល្អ " ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៧ ។

៨– ឯសេចក្ដីព្យាយាមនោះសោតដែលបុគ្គលនឹងធ្វើឲ្យពេញទីបាននោះ, ក៏អាស្រ័យទឹងមានុះសេចក្ដីសន្ដោសត្រេកអរចំពោះតែកិច្ចណាដែលខ្លួនត្រូវធ្វើម្យ៉ាងប៉ុណ្ណោះ ទើបបណ្ដោយឲ្យចិត្តរសាត់ទៅជាប់នឹងកិច្ចឯទៀតផ្សេងៗ ខុសពីកិច្ចដែលខ្លួនត្រូវធ្វើ ដូចសុភាសិតថា: " ចាប់នេះចាប់នោះ មិនខ្ជាប់ខ្ជួនណាហើយ ក៏មុខជានាំឲ្យកិច្ចដែលត្រូវធ្វើនោះៗរាយមាយទៅមិនសម្រេចប្រយោជន៍ឡើយ " ហេតុនេះហើយបានជាសម្ដេចព្រះមហាករុណាទិគុណជាម្ចាស់ទ្រង់លើកយក សន្តោស: ( សេចក្ដីសន្ដោ.ស ) ឡើងត្រាស់ទេសនាថាជាធម៌ធ្វើទីពឹង គំរប់ ៨ ។

ឯគុណធម៌នេះ ជាធម្មជាតិយ៉ាងសំខាន់បំផុតខាងឯជួយឧបត្ថម្ភឲ្យសេចក្ដីព្យាយាមនោះមានកម្លាំងឡើង គឺកាលបើបុគ្គលណាមួយបានធ្វើសេចក្ដីសន្ដោសត្រេកអរចំពោះតែវត្ថុជារបស់ខ្លួន ឬការងារដែលខ្លួនត្រូវធ្វើតែម្យ៉ាងប៉ុណ្ណោះ បុគ្គលនោះក៏នឹងមានសេចក្ដីប្រឹងប្រែងចំពោះតែកិច្ចការដែលខ្លួនត្រូវការ, មិនយូរប៉ុន្មានក៏នឹងបានសំរេចសេចក្ដីសុខសេចក្ដីចំរើន ដែលកើតអំពីសេចក្ដីព្យាយាមនោះដោយឆាប់រហ័ស សេចក្ដីនេះដូចម្ដេចមិញ ការដែលប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនាក៏ដូចគ្នា គឺកាលបើបុគ្គលណាមួយ មានសេចក្ដីសន្ដោសត្រេកអរចំពោះតែវត្ថុជារបស់ខ្លួនតាមមានតាមបាន ឬចំពោះវិជ្ជាដែលត្រូវរៀនសូត្រ មិនបណ្ដោយឲ្យសេចក្ដីលោភច្រើនហួសប្រមាណពេក ឬមិនបណ្ដោយឲ្យសេចក្ដីរវើរវាយមកគ្របសង្កត់ចិត្តឡើយ ក៏ជាហេតុឲ្យប្រឹងធ្វើចំពោះតែកិច្ចការដែលត្រូវធ្វើ នឹងវិជ្ជាចំណេះដែលត្រូវរៀនសូត្រនោះ ឲ្យរឹងរិតតែមាំមួនឡើង ដំណអំពីនោះទៅ ក៏នឹងបានសំរេចផលប្រយោជន៍ដែលកើតអំពីសេចក្ដីប្រឹងប្រែងនោះជាលំដាប់ ។ ព្រោះហេតុដូចអធិប្បាយមកនេះ សន្តោសៈ (សេចក្ដីសន្ដោស) ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៨ ។

ឯសេចក្ដីសន្ដោសនោះសោត ដែលបុគ្គលនឹងធ្វើឲ្យកើតក្លៀវក្លាឡើងបាន ក៏គោងអាស្រ័យ សតិ គឺស្មារតី សេចក្ដីរលឹកឃើញ

មកជាគ្រឿងឧបត្ថម្ភជាគ្រឿងទ្រផងទើបបាន បើមិនមានគុណធម៌នេះ មកជួយឧបត្ថម្ភផងទេ សេចក្ដីសន្ដោសនោះក៏នឹងសាបសូន្យទៅដាច់ហើយ ព្រោះហេតុនោះ បានជាសម្ដេចព្រះសិរីសុគតបរមគ្រូជាម្ចាស់ទ្រង់លើកយក សតិ ឡើងសំដែងថា ជាធម៌ធ្វើទីពឹង គំរប់ ៩ ។

ដ្បិតគុណធម៌នេះ ជាធម្មជាតិយ៉ាងសំខាន់បំផុតក្នុងវេលាដែលប្រកបកិច្ចអ្វី ៗ គ្រប់យ៉ាងទាំងអស់ ។ សតិនេះមានលក្ខណៈឬមានភ្ញាក់ឆាវខាងនឹករលឹកដល់កិច្ចការគ្រប់យ៉ាងដែលបានធ្វើរួចមកហើយ ឬពាក្យសំដីដែលបាននិយាយរួចមកហើយ នឹងគំនិតដែលបានគិតទុកយូរៗ មកហើយក៏អាចនឹកឃើញថា: ដូចជាទើបនឹងធ្វើ ទើបនឹងនិយាយ ទើបនឹងគិតថ្មី ៗ បាន ដូចមានពុទ្ធភាសិតថា: សតិ លោកស្មឹ ជាគរោ “ សតិជាធម៌គ្រឿងភ្ញាក់រលឹកនៅក្នុងលោក ” ។ សតិគឺស្មារតីនេះឯងតែងធ្វើបុគ្គលឲ្យដាច់នឹកឃើញ ឬឲ្យដឹងទាន់ខ្លួនទៅក្នុងកិច្ចការទាំងពួង នឹងធ្វើបុគ្គលឲ្យជាកាលញ្ញូ គឺជាអ្នកស្គាល់កាលវេលាដ៏សមគួរ ៗ បុគ្គលដែលខ្វះសតិ រមែងឥតដំណឹងដែលហៅថាអកាលញ្ញូ មិនស្គាល់កាលវេលា ប្រហែលគ្នានឹងមនុស្សកំពុងដេកលក់ ដែលមិនអាចប្រកបកិច្ចការជាប្រយោជន៍ឲ្យសម្រេចបានដូច្នោះឯង ។ ចំណែកមនុស្សដែលមានសតិបរិបូណ៌មិនប្រហែសធ្វេសជាមនុស្សមានដំណឹងដាច់ មិនបង្អែរបង្អង់ឲ្យយឺតយូរ

តែងបានសម្រេចសេចក្ដីសុខ-ចម្រើន មិនលិចចុះក្នុងសេចក្ដីថោកទាបឡើយ ។ ប្រហែលគ្នានឹងមនុស្សដែលភ្ញាក់រលឹកហើយចេះប្រកបកិច្ចការជាប្រយោជន៍នឹងបង្ការភ័យអន្តរាយកុំឲ្យមានមកដល់ខ្លួនបាន ។ សេចក្ដីនេះ សមដូចពុទ្ធភាសិតថា: អប្បមាទេន តរតិ អណ្ណវំ “បុគ្គលតែងឆ្លងសមុទ្រគឺភពវដ្ដសង្សារដោយអប្បមាទ គឺមានស្មារតីមិនប្រហែសធ្វេស” ។ ព្រោះហេតុដូចពោលមកហើយនេះ សតិទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៩ ។

១០- ឯសតិ សេចក្ដីរឭកនោះសោត, ដែលបុគ្គលនឹងរឭកឲ្យឃើញត្រូវតាមគន្លងធម៌បាននោះ ក៏គង់អាស្រ័យនឹងបញ្ញាគឺ សេចក្ដីដឹងច្បាស់ឆ្លៀវឆ្លាសវាងវៃ ស្គាល់ត្រូវខុសអាក្រក់ល្អមកជួយឧបត្ថម្ភផងទើបបាន បើគ្មានគុណធម៌នេះមកជួយឧបត្ថម្ភផងទេ សតិនោះ ក៏នឹងទ្រេតទ្រោតទៅរលឹកនូវអារម្មណ៍ផ្សេង ៗ ដែលជាអារម្មណ៍នាំចិត្តឲ្យប្រព្រឹត្តខុស, លុះតែមានបញ្ញាជាគ្រឿងបំភ្លឺផ្លូវ ទើបសតិនោះនឹកឃើញត្រូវតាមផ្លូវធម៌ឡើងបាន, ហេតុនេះ បានជាសម្ដេចព្រះត្រៃលោកនាថជាម្ចាស់ទ្រង់លើកយក បញ្ញា ឡើងត្រាស់ទេសនាថាជាធម៌ធ្វើទីពឹង គំរប់ ១០ ។ ដ្បិតគុណធម៌នេះ ជាធម្មជាតិយ៉ាងសំខាន់បំផុតក្នុងពេលដែលប្រកបការគ្រប់យ៉ាង ហើយជាពន្លឺភ្លឺស្វាងវិសេសអាចនឹងបំភ្លឺឲ្យឃើញសេចក្ដីកំបាំង

ប្រាកដដល់ចិត្ត ដូចព្រះអាទិត្យដែលអាចបំភ្លឺឲ្យឃើញរបស់ក្នុងទីងងឹតបាន ដូចមានពុទ្ធភាសិតថា បញ្ញា លោកស្មិំ បជ្ជោតោ "បញ្ញាជាពន្លឺដ៏រុងរឿងក្នុងលោក" ។ ពន្លឺព្រះអាទិត្យព្រះចន្ទនឹងភ្លើងក៏ជារបស់ផ្ទុះបំភ្លឺឲ្យឃើញវត្ថុដែលកំបាំងបានដោយយ៉ាង ១ តែពន្លឺទាំងនោះផ្ទុះបំភ្លឺបានតែរបស់ខាងក្រៅ ៗ មិនអាចផ្ទុះបំភ្លឺសេចក្តីអាថ៌កំបាំងខាងក្នុងសន្តានរបស់មនុស្សឲ្យស្គាល់ថា នេះជាហេតុនៃទុក្ខ នេះជាហេតុនៃសុខ នេះជាហេតុសេចក្តីវិនាស នេះជាសេចក្តីចម្រើនដូច្នេះបាន.ឡើយ មានតែបញ្ញាម្យ៉ាងនេះហើយ ទើបអាចផ្ទុះបំភ្លឺឲ្យស្គាល់ហេតុផលនោះបានវិសេសជាងពន្លឺដទៃ ៗ ដូចមានពុទ្ធភាសិតថា: នត្ថិ បញ្ញាសមា អាភា "រកពន្លឺអ្វីឲ្យស្មើនឹងពន្លឺគឺបញ្ញានេះមិនមានឡើយ" ។ ម្យ៉ាងទៀត បុគ្គលដែលអាចសំអាតចិត្តឲ្យបរិសុទ្ធផុតស្រឡះអំពីសេចក្តីសៅហ្មង ហើយបានសម្រេចព្រះនិព្វាននោះ ក៏ព្រោះតែបញ្ញា បញ្ញានេះលោកប្រៀបដូចជាកែវភ្នែករបស់នរជន ព្រោះចេះពិនិត្យគយគន់រកទោសគ្រឿងមន្ទិលដែលជាប់នៅក្នុងចិត្ត ទោះបីតិចតួចក៏អាចសំឡឹងឃើញច្បាស់ហើយលះបង់ចោលចេញ បើទុកជាធ្លាប់ប្រឡាក់ប្រឡូសមកអំពីមុន ព្រោះសេចក្តីល្ងង់ខ្លៅ ក៏គង់ត្រឡប់ជាស្អាតបរិសុទ្ធបាន ដូចពុទ្ធភាសិតថា: បញ្ញាយ បរិសុជ្ឈតិ "បុគ្គលតែងបរិសុទ្ធចិត្តបានដោយសារបញ្ញា" ។

អ្នកមានបញ្ញា ទើបចេះគេចវេះចេញអំពីសេចក្ដីវិនាសហើយតាំងខ្លួនឲ្យរឹងដំហរនៅក្នុងសេចក្ដីចំរើនបាន ទីងអ្នកដែលអាចបីបាច់រក្សាខ្លួនឯងព្រមទាំងអ្នកដទៃឲ្យបានសុខស្រួលនោះ ក៏ព្រោះតែមានបញ្ញាឈ្លៀវឆ្លាសក្នុងឧបាយផ្សេងៗនេះឯង, ដូចពុទ្ធភាសិតថា: បញ្ញា ហេតំ បសាសតិ "បញ្ញាតែងគ្រប់គ្រងរក្សាបុរសនុ៎ះ" ។ ព្រោះហេតុនេះ បញ្ញាទើបលោកចាត់ជាធម៌ធ្វើទីពីរ គំរប់១០ ដោយប្រការដូច្នេះឯង ។

សំដែងមកអំពីនាថករណធម៌ ដោយសង្ខេបនេះ សន្មតថាចប់ប៉ុណ្ណេះ ។ សូមសិរីសួស្តីជោគជ័យមង្គលដោយអំណាចនៃធម្មទេសនាផ្សាយតាមវិទ្យុកម្ពុជានេះ សូមកើតមានដល់អស់ពួកពុទ្ធបរិសទ្យទាំងឡាយ ដែលបានស្ដាប់សំឡេងឮតាមឧឃោសនស័ព្ទក្នុងទីនានាសូមឲ្យឧបទ្រពអន្តរាយគ្រប់យ៉ាងវិនាសអន្តរាយកុំបីសេសសល់ឡើយ ។

ការសំដែងធម៌ទេសនាសន្មតចប់ដោយសង្ខេបបែបនេះ ឯវំ ដូចសេចក្តីរៀបរាប់មកនេះឯង ។

---

## យក្ស. ប្រេត, អសុរកាយ, ជាដើម

### មានពិតមែនឬ?

សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លក្ខណសំយុត្ត

យុនបណ្ណាគារក្រប៊ូ-ប៊ូ

ក្រសួងពុទ្ធសាសនបណ្ឌិត្យ ជាអ្នកប្រែ (១)

---

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវនជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះមហាមោគ្គល្លានត្ថេរ និងព្រះលក្ខណត្ថេរគង់នៅនាភ្នំគិជ្ឈកូដ និមន្តចុះពីភ្នំគិជ្ឈកូដចូលទៅក្នុងក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះមហាមោគ្គល្លានត្ថេរកាលចុះពីភ្នំគិជ្ឈកូដក៏ធ្វើនូវការញញឹមឲ្យប្រាកដក្នុងប្រទេសមួយ ។ ព្រះលក្ខណត្ថេរសួរអំពីការញញឹមនោះចំពោះព្រះមហាមោគ្គល្លានត្ថេរ ។ ឃាត់ថាកុំសួរខ្ញុំក្នុងទីនេះ ចាំទៅសួរខ្ញុំក្នុងសំណាក់ព្រះដ៏មានព្រះភាគចុះ ។

លុះព្រះថេរៈទាំងពីរអង្គចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់ពីបិណ្ឌបាតមកវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ទើបព្រះលក្ខណត្ថេរសួរព្រះមហាមោគ្គល្លានត្ថេរអំពីការញញឹម

---

១ មិនបានប្រែពេញតាមប្រយោគបាលីទេ ប្រែកាត់ខ្លីៗ ដើម្បីឲ្យងាយស្តាប់ ។

នោះ ៗ ព្រះមហាមោគ្គល្លានត្ថេរប្រាប់ថា ម្នាលអាវុសោលក្ខណៈ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដបានឃើញរាងឆ្អឹង កំពុងតែអណ្តែតទៅលើអាកាស ហ្វូងត្មាតក្អែករអាតដេញតាមឆាបចោមចឹកចោះហើយដណ្តើមនូវរាងឆ្អឹងនោះ ៗ ក៏ចេះតែស្រែកថ្ងូរ ទើបខ្ញុំគិតថា យីអើអស្ចារ្យណាស់ យីអើ មិនធ្លាប់កើតមានសោះឡើយ យីអើ សត្វបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរ យក្សបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរ ការបានអត្តភាពបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរតើ ៗ

គ្រានោះព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានចក្ខុមានញាណកើតពិតហើយ ដ្បិតថាសាវ័កដឹងឬឃើញសត្វបែបនេះ ឬថានឹងធ្វើសត្វបែបនេះឲ្យជាសាក្សីដល់តថាគតបាន ៗ សត្វនោះតថាគតធ្លាប់ឃើញមកអំពីមុនដែរ ប៉ុន្តែតថាគតមិនទាន់សំដែង បើតថាគតសំដែងអំពីរឿងសត្វនុ៎ះទៅ ជនទាំងឡាយដទៃមិនជឿពាក្យតថាគតទេ អ្នកណាមិនជឿពាក្យតថាគត ការមិនជឿរបស់អ្នកនោះនឹងនាំឲ្យខានបានប្រយោជន៍ នាំឲ្យបានតែសេចក្តីទុក្ខអស់កាលជាយូរអង្វែង ៗ សត្វនោះពីដើមជាអ្នកសម្លាប់គោក្នុងក្រុងរាជគ្រឹះនេះឯង ដោយវិបាករបស់កម្មនោះ អ្នកសម្លាប់គោនោះ ក៏ទៅឆេះក្នុងនរករាប់រយ

ពាន់ម៉ឺនសែនឆ្នាំជាច្រើន, ដោយសេសសល់វិបាកនៃកម្មនោះ ទើបបាន ត្រឡប់មកទទួលផល គឺត្រឡប់បានអត្តភាពបែបនេះ ។

(រឿងប្រេតដទៃតពីនេះទៅទៀត កំព្រះលក្ខណៈត្រូវជាអ្នកសួរ, ព្រះមហាមោគ្គល្លានត្រូវជាអ្នកឆ្លើយប្រាប់, ព្រះដ៏មានព្រះភាគទ្រង់ទទួលបញ្ជាក់ថា ប្រេតនោះៗ មានពិតប្រាកដមែន) ។

- ម្នាលអាវុសោ លក្ខណៈ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ ខ្ញុំបានឃើញចំរៀកសាច់ កំពុងតែអណ្តែតទៅលើអាកាស ហ្វូងត្មាតក្អែកអាតជេញតាមឆាបចោមចឹកចោះកើចដណ្តើមនូវចំរៀកសាច់នោះៗ ក៏បេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ! សត្វនុះជាអ្នកសម្លាប់គោពីដើម ក្នុងក្រុងរាជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញដុំសាច់ កំពុងតែអណ្តែតទៅលើអាកាស ហ្វូងត្មាតក្អែកអាតជេញតាមឆាបចោមចឹកចោះកើចដណ្តើមនូវដុំសាច់នោះៗ បេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ! សត្វនុះជាព្រានបក្សីអំពីដើម ក្នុងក្រុងរាជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញបុរសគ្មានស្បែកក្រៅ កំពុងតែអណ្តែតទៅលើអាកាស ហ្វូងត្មាតក្អែកអាតជេញតាមឆាបចោមចឹកចោះកើចដណ្តើមនូវ

បុរសនោះៗ ចេះតែស្រែកថ្ងូរ ៗ – ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកសម្លាប់ចៀមអំពីដើម ក្នុងក្រុងរាជគ្រឹះនេះឯង ៗ

– ខ្ញុំបានឃើញបុរសមានរោមដូចដាវ កំពុងតែអណ្តែតទៅលើអាកាស ដាវទាំងនោះរបស់បុរសនោះអណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះឯងៗ ក៏ចេះតែស្រែកថ្ងូរ ៗ – ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកសម្លាប់ជ្រូកអំពីដើម ក្នុងក្រុងរាជគ្រឹះនេះឯង ៗ

– ខ្ញុំបានឃើញបុរសមានរោមដូចព្រួញ កំពុងតែអណ្តែតទៅលើអាកាស ព្រួញទាំងនោះរបស់បុរសនោះអណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះឯងៗ ក៏ចេះតែស្រែកថ្ងូរ ៗ – ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាពេជ្ឈឃាដអំពីដើមក្នុងក្រុងរាជគ្រឹះនេះឯង ៗ

– ខ្ញុំបានឃើញបុរសមានរោមដូចដែកស្រួច កំពុងតែអណ្តែតទៅលើអាកាស ដែកស្រួចទាំងនោះរបស់បុរសនោះអណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះវិញ បុរសនោះក៏ចេះតែស្រែកថ្ងូរ ៗ – ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកបរគោអំពីដើម ក្នុងក្រុងរាជគ្រឹះនេះឯង ៗ

– ខ្ញុំបានឃើញបុរសមានរោមដូចដែកស្រួច កំពុងតែអណ្តែតទៅលើអាកាស ដែកស្រួចទាំងនោះរបស់បុរសនោះក៏ដោតចូលទៅក្នុងក្បាលធ្លាយចេញមកតាមមាត់ ដោតចូលទៅក្នុងមាត់ធ្លាយចេញមកតាមទ្រូង

ដោតចូលទៅក្នុងទ្រូងធ្លាយចេញមកតាមពោះ ដោតចូលទៅក្នុងពោះធ្លាយចេញមកតាមភ្លៅ ដោតចូលទៅក្នុងភ្លៅធ្លាយចេញមកតាមស្មង ដោតចូលទៅក្នុងស្មង ធ្លាយចេញមកតាមបាតជើង ។ បុរសនោះក៏ចេះតែស្រែកថ្ងូរ ៗ - ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកចាក់ដោតគីញុះញង់គេអំពីដើម ក្នុងក្រុងរាជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញបុរសមានអណ្ឌៈ (ពងល្វា) ប៉ុនក្អម កំពុងតែអណ្តែតទៅលើអាកាស កាលបុរសនោះដើរទៅលុះតែលើកអណ្ឌៈទាំងនោះដាក់ត្រង់កលី ទើបដើរទៅបាន កាលអង្គុយក៏អង្គុយសង្កត់លើអណ្ឌៈទាំងនោះឯង ហ្វូងត្មាតក្អែកអាតដេញតាមឆាបចោមចឹកចោះកើចដញ្ជែងខ្លួនបុរសនោះៗ ក៏ចេះតែស្រែកថ្ងូរ ៗ - ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកកាន់អំពើវៀចក្នុងស្រុក គឺជាអាមាត្យអ្នកវិនិច្ឆ័យក្តីដោយទុច្ចរិតអំពីដើមក្នុងក្រុងរាជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញបុរសម្នាក់ កំពុងតែមុជក្បាលចុះទៅក្នុងរណ្តៅលាមក ។ - ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកប្រព្រឹត្តបរទារិកកម្មគឺលួចប្រពន្ធអ្នកដទៃពីដើម ក្នុងក្រុងរាជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញបុរសម្នាក់កំពុងតែមុជទៅក្នុងរណ្តៅលាមក ចាប់លាមកដោយដៃទាំងពីរស៊ី ។ - ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះពីដើមជា

ព្រាហ្មណ៍ក្នុងក្រុងរាជគ្រឹះនេះឯង ។ ព្រាហ្មណ៍នោះ កាលក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ បាននិមន្តភិក្ខុសង្ឃដោយភត្តាហារ ក៏ដាក់លាមកពេញក្នុងស្លឹក រួចហើយប្រើគេឲ្យប្រាប់ភត្តកាល ហើយនិយាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តឆាន់ដរាបដល់ឆ្អែតផង សូមនិមន្តយកទៅផង ។

— ខ្ញុំបានឃើញស្រីគ្មានស្បែកក្រៅ កំពុងតែអណ្តែតទៅលើអាកាស ហ្វូងត្មាតក្អែករអាតដេញតាមឆាបចោមចឹកចោះហើចដញ្ហែងនូវស្រីនោះៗ ក៏បេះតែស្រែកថ្ងូរ ៗ — ម្នាលភិក្ខុទាំងឡាយ ស្រីនោះកាលពីដើមជាស្រីប្រព្រឹត្តកន្លងប្តីក្នុងក្រុងរាជគ្រឹះនេះឯង ។

— ខ្ញុំបានឃើញស្រីមានរូបអាក្រក់ ដែលបុរសគួរខ្ពើមមានក្លិនស្អុយ កំពុងតែអណ្តែតទៅលើអាកាស ហ្វូងត្មាតក្អែករអាតដេញតាមឆាបចោម-ចឹកចោះហើចដញ្ហែងនូវស្រីនោះៗ ក៏បេះតែស្រែកថ្ងូរ ៗ — ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះកាលពីដើមជាស្រីមេមត់ ក្នុងក្រុងរាជគ្រឹះនេះឯង ។

— ខ្ញុំបានឃើញស្រីមានកាយឆេះរោលរាលដោយភ្លើង មានកាយសើមជោកជាំ មានកាយដេរដាសដោយរងើកភ្លើង កំពុងតែអណ្តែតទៅលើអាកាស ស្ត្រីនោះក៏បេះតែស្រែកថ្ងូរ ៗ — ម្នាលភិក្ខុទាំងឡាយ

ស្រីនុះកាលពីដើមជាអគ្គមហេសី នៃស្ដេចកុងដែនកលិង្គ ស្រីនោះជាអ្នកមានសេចក្ដីប្រច័ណ្ឌ ក្រឡែកឃើញស្ត្រីសង្កត់ បានចាក់ស្រោចភ្លើងមួយអំបែងលើស្ត្រីជាមហេសីចុង ។

- ខ្ញុំបានឃើញប្រេតគ្មានក្បាល កំពុងតែអណ្ដែតទៅលើអាកាស ប្រេតនោះមានភ្នែកនិងមុខនៅត្រង់ទ្រូង ហ្វូងត្មាតក្អែកអោតដេញតាមចាបចោមចឹកចោះកើបដណ្ដើមនូវប្រេតនោះៗក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ សត្វនុះកាលពីដើមឈ្មោះហារិកៈជាអ្នកពិឃាដចោរក្នុងក្រុងរាជគ្រឹះនេះឯង ។

- ម្នាលអាវុសោ លក្ខណៈ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ ខ្ញុំបានឃើញភិក្ខុ, ភិក្ខុនី, សិក្ខមានា, សាមណេរ, សាមណេរី កំពុងតែអណ្ដែតទៅលើអាកាស សង្ឃាដី, បាត្រ, វត្តពន្ធ, ចង្កេះនិងកាយរបស់ភិក្ខុ ។ល។ សាមណេរីនោះ មានភ្លើងឆេះសន្ធោសន្ធៅ ភិក្ខុ ។ល។ សាមណេរីនោះក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ។ល។ សាមណេរីនុះកាលពីដើមជាភិក្ខុ ។ល។ ជាសាមណេរីលាមក ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។

ចប់

ការបណ្តុះនិស្ស័យ

# ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណាធរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

---

៤— អើពើស្តាប់បង្គាប់គ្នា.— មនុស្សយើងដែលនៅរួមគ្នាជាពួកគណៈ រមែងមានទាំងអ្នកធំទាំងអ្នកតូច ៗ ដូច្នេះ អ្នកធំគួរអើពើចំពោះអ្នកតូច ទាំងអ្នកតូចក៏គួរអើពើស្តាប់បង្គាប់អ្នកធំ ៗ សម្រាប់អ្នកធំ ត្រូវឲ្យស្គាល់ខុស-ត្រូវ-អាក្រក់ ល្អ និងវត្ថុដែលជាគុណជាទោសច្រើនជាងអ្នកតូច ទាំងមាននាទីគ្រប់គ្រងមើលថែរក្សាបង្គាប់បញ្ជា-ណែនាំប្រៀនប្រដៅអ្នកតូច ឲ្យធ្វើតែអំពើដែលជាប្រយោជន៍ ឲ្យវៀរអំពើជាទោសដែលអាចនាំមកនូវទុក្ខភ័យ ក្តៅក្រហាយផ្សេងៗ ៗ សម្រាប់អ្នកតូច ទោះមានចំណេះដំណឹងតិចជាង ឬច្រើនជាងក៏ដោយ តែដើម្បីទទួលអំណាចដ៏ត្រឹមត្រូវតាមច្បាប់និងភាពជាអ្នកជាចំពោះខ្លួន ក៏គួរស្តាប់បង្គាប់អ្នកធំដែលមានអំណាចដ៏ត្រឹមត្រូវតាមច្បាប់លើខ្លួន ៗ ពិតមែន! អ្នកធំនឹងមានអំណាចបាន ព្រោះអ្នកតូចស្តាប់បង្គាប់តាំងចិត្តធ្វើតាមពាក្យប្រៀនប្រដៅ ៗ សូម្បីអ្នកតូចនឹងមានអំណាច ទាំងមានភាពជាអ្នកជាចំពោះខ្លួនបានក៏ព្រោះការស្តាប់បង្គាប់ តាំងចិត្តធ្វើតាមពាក្យប្រៀន

ប្រដៅរបស់អ្នកធំ ។ គ្រាណាដែលអំណាចនិងមតិមហាជនរួមផ្សំគ្នា គ្រានោះ អំណាចរមែងខ្ពស់ឡើង គ្រាណា អំណាចផ្ទុយគ្នានឹងមតិមហាជន គ្រានោះ អំណាចរមែងដល់នូវកាលអវសាន ( ផុតរលត់ ) ។ ហេតុនេះ ដើម្បីឲ្យបានសន្តិសុខៈរៀបរយនៃពួកគណៈ អ្នកធំនិងអ្នកតូចត្រូវធ្វើឲ្យត្រូវបានៈ ឲ្យត្រូវអធ្យាស្រ័យគ្នា គឺអ្នកធំកាន់នាទីជាអ្នកអើពើផ្សាយមេត្រីចំពោះអ្នកតូចដែលនៅក្រោមបង្គាប់, អ្នកតូច កាន់មុខក្រសួងខាងការស្តាប់បង្គាប់-គោរពអ្នកធំដែលនៅលើខ្លួន ដោយចេះរំងាប់អារម្មណ៍អាក្រក់ ចេះធ្វើសេចក្តីល្អកងទីតាំងពួង ។

អ្នកធំ ចូរអើពើអនុគ្រោះដល់អ្នកតូចតាមនាទី ដោយការគ្រប់គ្រង-មើល-ថែទាំ បង្គាប់បញ្ជា ណែនាំប្រៀនប្រដៅ ដោយមេត្តាករុណា ។ ចូរជ្រាបចុះថា កាលបើជាតិចំរើនហើយ អ្នកតូចរមែងស្គាល់ពេលវេលាដែលគួរស្តាប់ ឬ មិនគួរស្តាប់ នូវពាក្យបញ្ជូន ឬ បង្គាប់បញ្ជា ។ ដូចេះ អ្នកធំដែលជាមនុស្សខ្ពស់ជាងអ្នកតូច ហើយដែលត្រូវឃុំគ្រងអ្នកតូចនោះត្រូវស្គាល់ថា វត្ថុណាត្រូវច្បាប់ គួរបង្គាប់ វត្ថុណាខុសច្បាប់ មិនគួរបង្គាប់ បើនឹងបង្គាប់ជំរុលទៅដោយមិនស្គាល់ថាគួរឬមិនគួរទេ លុះកាលអ្នកតូចនៅក្រោមបង្គាប់មិនធ្វើតាម ឬ ធ្វើមិនកើតសម្បូរទឹងប្រើអំណាចកំហែងបង្ខំទៅ ក៏គង់មិនបានសម្រេចផលគង់ចូលក្នុងទំនងថា "ប្រើដំរីឲ្យចូលរន្ធគូថមួល" ឯអ្នកដែលប្រើអំណាចខុសច្បាប់ បង្ខំកំហែងគេបសង្កត់អ្នកដទៃនោះ មុខជាត្រូវគេតប

ស្នងសងគុណមកវិញ ដោយអំណាចដូច្នោះ គ្មានកាលដែលខ្លួនអស់អំណាចពុំខាន មើលពស់វែកចុះ កាលអស់អំណាចហើយក៏ត្រូវហ្វូងស្រមោចស៊ីបាន ។

អ្នកតូចត្រូវបង្អោនខ្លួននៅក្រោមបង្គាប់បញ្ជារបស់អ្នកធំ ដែលគ្រប់គ្រង ឬមានអំណាចលើខ្លួនដែលជាអ្នកមានដំណើរ (សេចក្ដីដឹង) ឈ្លាសវៃអាចគ្រប់គ្រងនឹងបង្គាប់បញ្ជាខ្លួនបាន នឹងត្រូវជាមនុស្សប្រដៅងាយ ដាក់កាយដាក់ចិត្ត គោរព-រាប់អាន-ស្ដាប់បង្គាប់ តាំងចិត្តធ្វើតាមទុកទដែលលោកណែនាំប្រៀនប្រដៅ ដោយកាន់បែបផែនទំនៀមទំលាប់ សេចក្ដីបង្គាប់ ទុកជាគ្រូនៅក្នុងចិត្តយ៉ាងខ្ជាប់ខ្ជួន ។ ព្រោះកាលអ្នកតូចស្ដាប់បង្គាប់អ្នកធំ នឹងប្រតិបត្តិត្រឹមត្រូវតាមគួរ ឲ្យជាទីទុកចិត្តបានហើយ អ្នកធំក៏រមែងឲ្យភាពជាអ្នកជាដល់ខ្លួនក្នុងចំណែកនាទីរបស់ខ្លួន គោលគឺទុកចិត្តយល់ព្រមឲ្យទទួលខុស-ត្រូវក្នុងចំណែកខ្លួនតាមធម្មតា តែបើអ្នកតូចប្រកាន់យកភាពជាអ្នកជាចំពោះខ្លួនហួសប្រមាណថា "យើងស្គាល់ខុស-ត្រូវ-អាក្រក់-ល្អ ល្មមសមគួរហើយ មិនចាំបាច់ឲ្យអ្នកណាប្រៀនប្រដៅ មិនចាំបាច់ស្ដាប់បង្គាប់នរណា នឹងមិនចាំបាច់ធ្វើតាមពាក្យពន្យល់ ឬពាក្យបង្គាប់បញ្ជារបស់នរណាឡើយ" ដូច្នេះ សូម្បីមានអំណាចចំពោះខ្លួនយ៉ាងណា ក៏ឈ្មោះថាខុសធម្មតា ។

ការសិក្សាសូត្ររៀន និងការប្រព្រឹត្តល្អ ឬកិច្ចការដទៃៗ បើអ្នកធំមិនអើពើចំពោះអ្នកតូច ទាំងអ្នកតូចក៏មិនជឿមិនស្ដាប់អ្នកធំហើយ

ក៏ឥតបានសម្រេចផលអ្វីឡើយ បើជាការគ្រប់គ្រងពួកគណៈផង ក៏ប៉ុន គ្មានឹងធ្វើពួកគណៈឲ្យបែកបាក់ប្រេះឆាទៅបណ្ដាយ ដូចជាមេឃុំមិនអើពើចំពោះកូនឃុំ កូនឃុំមិនជឿ មិនស្ដាប់បង្គាប់ មេឃុំ, ចៅហ្វាយស្រុក មិនអើពើចំពោះមេឃុំ, មេឃុំមិនជឿមិនស្ដាប់បង្គាប់ចៅហ្វាយស្រុក, ចៅហ្វាយខេត្តមិនអើពើចំពោះចៅហ្វាយស្រុក, ចៅហ្វាយស្រុកមិនជឿមិនស្ដាប់ចៅហ្វាយខេត្ត, នាយក្រសួងតៗឡើងទៅទៀត ក៏មិនអើពើនឹងមិនស្ដាប់បង្គាប់គ្នាយ៉ាងនេះ ការគ្រប់គ្រងពួកគណៈ ក៏មុខជាត្រូវប្រែប្រួល នឹងកើតចលាចលមិនសុខស្រួលរៀបរយឡើយ ។

លក្ខណៈនៃនិស្ស័យកាន់អ្នកដទៃ គឺសំដែងកិរិយា វាចាសុភាពទន់ទាប ផ្អែមល្ហែមចំពោះគ្នា, ប្រព្រឹត្តខ្លួនឲ្យស្មោះស្មើចំពោះគ្នានឹងគ្នា, លើកដំកើងសរសើរគ្នា នឹងអើពើស្ដាប់បង្គាប់គ្នាទាំង ៤ ប្រការ ដូចពោលមកហើយនេះ រមែងជាផ្លូវគោចរមកនៃសេចក្ដីល្អ សេចក្ដីចំរើនចំពោះមនុស្សដែលនៅរួមគ្នាជាពួកគណៈ ៗ ព្រោះក្នុងពួកគណៈនោះ បើអ្នកធំកាន់អ្នកតូច ហើយអ្នកតូចស្ដាប់បង្គាប់អ្នកធំ ដោយសុទ្ធចិត្តពិតៗ កិច្ចការរបស់ពួកគណៈ ទាំងចំណែកខ្លួនទាំងចំណែករួមគ្នា ក៏ចំរើនរុងរឿងជារបៀបរៀបរយឡើង បើនិយាយដល់ចំណែកបុគ្គលផងហើយ និស្ស័យកាន់អ្នកដទៃនេះ រមែងជាគ្រឿងប្រដាប់សម្រាប់ធ្វើអ្នកធំ ឲ្យទៅជាទីគោរពសក្ការបូជារបស់អ្នកតូច នឹងជាគ្រឿងប្រដាប់សម្រាប់ថែរក្សាអ្នកតូចឲ្យជាទីគួរស្រឡាញ់ គួរទុកចិត្តរបស់អ្នកធំ

ទាំងសងខាងក៏ស្រឡាញ់គោរពរាប់អាន ព្រមព្រៀងគ្នាមុឹងម៉ាត់ពេញទី ប្រៀបដូចទឹកបន្ទ្យារដែលតឲ្យជាប់គ្នារលាយសាច់ ១ ដូច្នោះ សូម្បីកាលមានហេតុត្រូវបែកបាក់គ្នាកើតឡើង ក៏ព្យាយាមរំងាប់ការប្រេះឆានោះ មិនឲ្យខ្ចរខ្ចាយសាយភាយចេញទៅ ទាំងមិនសំដែងវិការៈ កាយ វាចា ឲ្យប្រាកដ នៅតែធ្វើសេចក្តីគោរពរាប់អានស្រឡាញ់គ្នាដូចដើម ប្រៀបដូចជាចងក្រៀករបស់ដែលបែកខ្ញែកឲ្យនៅជាប់មូលគ្នា មិនឲ្យខ្ចាត់ខ្ចាយរាត់រាយទៅដូច្នោះ ៗ

ដោយន័យនេះ យើងទើបអាចឃើញបានថា លក្ខណៈនៃនិស្ស័យរាប់អានអ្នកដទៃទាំង ៤ យ៉ាងនោះ រមែងជាវិថីនាំជីវិតរបស់យើង ឲ្យឈានទៅកាន់សេចក្តីចំរើនរុងរឿងជាស្ថាពរបានច្រើនប្រការ គឺឲ្យកើតសេចក្តីនិយមរាប់អាន ស្រឡាញ់រាក់ទាក់នឹងគ្នា មិនរាំងទាស់នឹងគ្នា, ឲ្យបានទទួលអនុគ្រោះក្នុងការសិក្សាសិប្បវិជ្ជាអំពីគ្នា ដោយសេចក្តីត្រេកអរនឹងពេញចិត្ត, ឲ្យកិច្ចការដំណើរទៅដោយសួស្តី ប្រាសចាកឧបសគ្គ ឲ្យកើតសេចក្តីសាមគ្គីនឹងគ្នាក្នុងរវាងបុគ្គលនិងពួកគណៈ ឲ្យជាមនុស្សទូលំទូលាយក្នុងពួកគណៈ អាចចូលសមាគមណា ៗ ក៏ចូលបាន, ឲ្យកើតកិត្តិយសក្នុងការទទួលអញ្ជើញ ទទួលស្តាប់បង្គាប់ដោយអធ្យាស្រ័យមេត្រី នឹងឲ្យកើតសន្តិសុខ រៀបរយដល់គ្នានឹងគ្នា ដែលជាផ្លូវនាំឲ្យកើតសេចក្តីត្រជាក់ត្រជុំដល់អ្នកតូច នឹងឲ្យកើតការផ្គាប់ចិត្តដល់អ្នកធំបាន ៗ

(មានត)

# រឿងសាមកុក

## កណ្ឌទី ១៧

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

លីប៉ោបានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរពន់ពេក ហើយបាននិយាយទឹងគាន់តេងថា ឥឡូវចូចូលើកចូលមកព័ទ្ធជុំកំពែងស្រុកហើយ បើនឹងនៅក្រុងចូលទៅបន្ទាយគយមិនបាន ឲ្យអ្នកឯងស្លូតទៅមុនដើម្បីនឹងប្រាប់តាន់កុងថា យើងនឹងលើកទ័ពទៅដល់ក្នុងវេលាយប់នេះ ឲ្យចាំបើកទ្វារទទួលហើយអុជភ្លើងសញ្ញាឡើង យើងនឹងលើកពលពារទំលាយទ័ពចូចូចូលទៅឲ្យបាន ។ គាន់តេងក៏លាលីប៉ោស្លូតទៅគយសៀវគួនជាមុន លុះដល់ហើយក៏ប្រាប់តាន់កុងថា ខ្ញុំបាននាំដំណឹងទៅជំរាបលីប៉ោៗ ក៏យល់ឃើញត្រូវដូចគំនិតខ្ញុំ ឥឡូវលីប៉ោផ្តាំមកថា កម្លាំងទ័ពចូចូខ្លាំង

ពន្ទឹកណាស់ ឃើញថាលោកនឹងតទល់មិនបានទេ ព្រោះគយសៀវគួននេះមិនមែនជាទីសំខាន់ ឲ្យលើកទ័ពទៅស្រុកឈើជីវនឹងបានជួយលីប៉ៅគិតគូរគ្នាការពារស្រុក ៗ តាន់កុងមិនដឹងក្នុងកលតាន់តេងក៏សំគាល់ថាមែន លុះពេលយប់ក៏នាំទាហានរត់ចោលបន្ទាយគយនោះទៅ មិនបានប្រាប់នាយចោរទាំង ៤ ឲ្យដឹង ៗ ខណៈកាលតាន់កុងលើកពលរត់ទៅនោះ តាន់តេងក៏លបដុតភ្លើងឆេះឡើងក្នុងបន្ទាយ ទទួលលីប៉ៅលើកទ័ពមកដល់ក្រឡេកឃើញពន្លឺភ្លើងភ្លឺឡើង ក៏សំគាល់ថាតាន់កុងអុជទទួល ក៏បង្ហឹបពលចូលទៅជួបនឹងតាន់កុងដែលកំពុងរត់ចេញមក ៗ លីប៉ៅសំគាល់ថាកងទ័ពប៊ូឆូក៏ដេញទាហានចូលប្រកាប់ជាប់ដៃគ្នា ខាងតាន់កុងមិនដឹងថាលីប៉ៅសំគាល់ថា ទ័ពប៊ូឆូលើកចូលមកស្ទាក់ពីមុខ ក៏ដេញពលចូលគ្រលុកដើម្បីនឹងទំលាយចេញទៅ ទាហានទាំងសងខាងក៏ចាក់កាប់សម្លាប់គ្នាស្លាប់ជាច្រើនណាស់ ៗ

ឯប៊ូឆូឃើញភ្លើងឆេះក្នុងបន្ទាយដូចសំបុត្រសញ្ញាតាន់តេង ក៏ដេញពលចូលទៅការទំលាយបន្ទាយ នាយចោរទាំង ៤ នាក់ដែលនៅរក្សាគយនោះ មិនបានដឹងការថាយ៉ាងម្ដេច ក៏ប្រមូលទាហានចេញទៅតតាំងច្បាំងគ្នានឹងកងទ័ពប៊ូឆូជាពន្ទឹក ៗ ពួកចោរនោះមានទាហានតិចតស៊ូនឹងកងទ័ពប៊ូឆូមិនបាន ក៏បាក់បែកខ្ចាត់ខ្ចាយរត់យកតែខ្លួន ៗ ប៊ូឆូក៏លើកពលចូលទៅតាំងនៅក្នុងគយសៀវគួនបាន ៗ

ឯលីប៉ោទឹងតាន់កុងវង្វេងប្រឡំតាក់កាប់សម្លាប់គ្នា ត្រាតែថ្ងៃរះទាហានទាំងសងខាង ក៏ក្រឡេកឃើញមុខគ្នាច្បាស់ស្គាល់ជាទ័ពគ្នាឯងក៏ឈប់ប្រកាប់គ្នា តាន់កុងម្នីម្នាចូលទៅជួបទឹងលីប៉ោ ពណ៌នាពាក្យរឿងឲ្យលីប៉ោស្តាប់គ្រប់ប្រការ លីៈប៉ោទឹងតាន់កុងក៏ដឹងច្បាស់ថា។ ហេតុដែលកើតជាចលាចលដូច្នេះដោយសារឧបាយកលតាន់តេង លីប៉ោក៏នាំសេនាទាហានទាំងអស់ស្រូតត្រឡប់ទៅស្រុកឈីជីវ លុះដល់ជើងកំពែងលីប៉ោក៏ហៅសេនាទាហានដែលយាមល្បាតឲ្យបើកទ្វារទទួល ។

ឯប៊ុតុកឃើញកងទ័ពលីប៉ោលើកចូលមកស្រុកឲ្យបើកទ្វារ ក៏បង្គាប់ឲ្យទាហានដែលនៅលើសើនលើកធ្នូបាញ់ចម្រុះចុះទៅ ហើយប៊ុតុកស្រែកប្រាប់លីប៉ោថា ស្រុកឈីជីវៈនេះមិនមែនជារបស់លីប៉ោឯងទេ គឺជាស្រុកទៀតពីចៅហ្វាយយើង កាលពីមុននោះ ឯងបានមកដណ្តើមយក ឥឡូវយើងមកដណ្តើមយកវិញ ចូរឯងលើកទាហានត្រឡប់ទៅវិញចុះ ។

លីប៉ោភ័យស្លុតចិត្តក៏ស្រែកសួរប៊ុតុកថា តាន់គុយដែលយើងឲ្យនៅរក្សាស្រុកនេះឥឡូវទៅឯណាទៅហើយ ? ប៊ុតុកឆ្លើយថា តាន់គុយនោះយើងចាប់ខ្លួនសម្លាប់ទៅហើយ ។ លីប៉ោបានឮដូច្នោះទើបងាកមកសួរតាន់កុងថា តាន់តេងបានមកជាមួយដែរឬទេ? ។ តាន់កុងឆ្លើយថា ហេតុដូចម្តេចលោកនៅសួររកឈ្មោះអាសត្វនោះទៀត ។ លីប៉ោក៏ឲ្យត្រួតពិនិត្យមើលក្នុងពួកទាហានមិនឃើញតាន់តេងសោះ ។ តាន់កុងនិ-

យាយទឹងលីប៉ោថា ដែលយើងទឹងលើកចូលកាប់ទំលាយយកស្រុកឈើ-ដីវគ្រានេះ ជាការទុញទាល់ហើយ សុំឲ្យលោកលើកទាហានទៅស្រុកសៀវផាយចុះ ទឹងបានរិះគិតគ្នាទឹងកោស៊ុន តៀវលៀវ ហើយលើកទ័ពត្រឡប់មកយកស្រុកយើងឲ្យបានវិញ ។ លីប៉ោយល់ឃើញត្រូវ ក៏លើកកងទ័ពទៅស្រុកសៀវផាយ ។

ឯតាន់តេង កាលលបដុតភ្លើងឆេះឡើងក្នុងបន្ទាយគយសៀវគួន ហើយ ក្រឡេកមើលទៅឃើញទាហានលីប៉ោទឹងទាហានតាន់ក្នុងវង្វេង កាប់សម្លាប់គ្នាជាពន្លឹកដូច្នោះ តាន់តេងក៏លបចេញពីក្នុងបន្ទាយសៀវគួន ស្រូតរូតទៅស្រុកសៀវផាយប្រាប់កោស៊ុន, តៀវលៀវថា ម្សិលមិញ ចូចូលើកទ័ពមកឡោមព័ទ្ធលីប៉ោ ។ តស៊ូទឹងចូចូមិនបាន ក៏ប្រើខ្ញុំឲ្យមក រកអ្នកដើម្បីឲ្យអ្នកលើកទាហានទៅជួយ ។ កោស៊ុន តៀវលៀវក័យ សុតចិត្តសំគាល់ថាពិតប្រាកដ ក៏លើកទាហានចេញពីស្រុកសៀវផាយ ទៅជួយលីប៉ោ ។ ឯតាន់តេងក៏ចេញទៅរកហោយិន ហើយនាំយក កងទ័ពហោយិនចូលទៅតាំងនៅក្នុងស្រុកសៀវផាយ ។

ឯកោស៊ុនទឹងតៀវលៀវ លើកទ័ពទៅដល់កណ្តាលផ្លូវ ប្រទះ ទឹងទ័ពលីប៉ោលើកមក ក៏ចូលទៅជួបទឹងលីប៉ោ ។ ទឹកទ្ទល់ក្នុងចិត្ត ក៏ សាកសួរកោស៊ុនទឹងតៀវលៀវថា យើងចាត់ប្រើខ្លួនឲ្យនៅត្រួតត្រា រក្សាស្រុកសៀវផាយ ហេតុម្តេចខ្លួនចេញចោលស្រុកមកដូច្នេះ ? ។

(មានត)

# រឿងអាវ័គ្យថ្លែងរឿងម្ភៃប្រាំ

## លោក រ៉ាយ-ប៊ុក ក្រុមការ

*ប្រែពីបារាំងមកជាខ្មែរ*

(តមក)

---

## រឿងទីម្ភៃបី

អាវ័គ្យក្រាបបង្គំទូលព្រះនរបតីថា: "បពិត្រព្រះករុណាថ្លៃវិសេស! ក្នុងអតីតកាលមាននគរ ១ ឈ្មោះ ធម៌បុរ: (Dharmapur) (បុរីនៃជនប្រព្រឹត្តធម៌) ព្រះមហាក្សត្រិយ៍ទ្រង់ព្រះនាមព្រះបាទធម្មជ: (Dharmaj) សោយរាជ្យក្នុងនគរនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះគោវិន្ទ (Gôbind) ជាអ្នកចេះវេទទាំងបួននឹងសាស្ត្រទាំងប្រាំមួយ បានបំពេញករណីយកិច្ចខាងសាសនា, ព្រាហ្មណ៍នេះមានបុត្រ៤នាក់គឺ: ហរិទត្ត(Haridatt) ១, សោមទត្ត (Sômadatt) ១, យគ្យទត្ត (Yagya 'att) ១, នឹងព្រហ្មទត្ត (Brahmadatt) ១, ជាបណ្ឌិត ជាសន្តបុគ្គល ហើយតែងតែនៅក្រោមឪវាទបិតាជានិរន្តរ៍ ។

ក្រោយមក, កូនច្បងនៃព្រាហ្មណ៍នោះទទួលអនិច្ចកម្ម ហើយខ្លួនលោកជិតនឹងទទួលមរណភាពដោយកើតទុក្ខធំនេះ ស្រាប់តែលោកវិស្ណុសម៌: (Vishnusharma) ជាគ្រូព្រះមហាក្សត្រិយ៍បានអញ្ជើញទៅកាន់

គេហដ្ឋានរបស់គោរិន្ទព្រាហ្មណ៍ហើយពោលថា: "មនុស្សយើងតែងតែ មានទុក្ខតាំងពីចូលមកនៅក្នុងផ្ទៃមាតា ។ ដល់មកយុវនភាពមនុស្ស យើងតែងលុះក្នុងកណ្ដាប់ដៃនៃតណ្ហា (សេចក្ដីស្នេហា), ទំរង់នូវសេចក្ដី លំបាកដែលកើតឡើង ដោយការព្រាសព្រាត់ចាកសត្វនិងសង្ខារដែល ជាទីស្រឡាញ់ពេញចិត្ត ។ ដល់វ័យចាស់, រូបកាយក៏ទុព្វលភាព ហើយធ្លាក់ទៅក្នុងទុក្ខលំបាកគ្រប់យ៉ាង ។ បើពោលដោយសង្ខេប, តាំងពីថ្ងៃដែលយើងបដិសន្ធិមក, យើងតែងជួបប្រទះនឹងទុក្ខច្រើនជាង សុខ ព្រោះថាពិភពលោកនេះជាអនន្តទុក្ខ ។

"បើទុកជាឡើងទៅនៅលើចុងឈើក្ដី, ស្ថិតនៅលើខ្នងភ្នំក្ដី, ចូល ទៅពួនសម្ងំនៅក្រោមបាតសមុទ្រក្ដី, ចូលទៅនៅក្នុងទ្រុងដែកក្ដី ចូល ទៅពួននៅក្នុងស្ថាននរកក្ដី, ក៏ព្រះកាលមិនយោគយល់អ្នកនោះឡើយ ។

"បើទុកជាអ្នកនោះជាបណ្ឌិត ឬល្ងង់ខ្លៅ, មាន ឬក្រ មានវិចារ-ណញ្ញាណ ឬមិនមាន ខ្លាំង ឬខ្សោយ ក៏ព្រះកាលដែលធ្លាប់តែលេប សត្វនិងសង្ខារទាំងអស់ មិនយោគយល់សោះឡើយ ។

"មនុស្សតែងរស់នៅ បើយ៉ាងយូរ ១០០ ឆ្នាំ, ហើយក្នុងពាក់-កណ្ដាលនៃជីវភាពសព្វៗខ្លួន ស្ថិតនៅក្នុងការដេកលក់, ពាក់កណ្ដាល ទៀត ស្ថិតនៅក្នុងវ័យក្មេង, ជរា, ហើយក្រៅពីនេះ រស់នៅដោយទុក្ខ, ការជំលោះ និងការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ពេញ ចិត្ត ។ ជីវិតប្រែប្រួលដូចរលកទឹក តើត្រង់ណាដែលហៅថាសុខ? ។

" ឥឡូវៈយើងបានមកដល់វ័យទៅ ( ប្រហែលជាចាស់ជរា ! ), យើងមិនដែលបានជួបប្រទះនឹងមនុស្សដែលគោរពសច្ចធម៌ ។ ក្នុងមួយថ្ងៃ មានកូមិកាគះគេចូលទៅលុកលុយខ្ទេចខ្ទីអស់គ្មានសល់, ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះទ័យកំណាញ់, ផែនប្រថពីឲ្យផលានុផលកាន់តែតិចៗទៅ, ពួកចោរកាចសាមាន្យប្រព្រឹត្តលួចប្លន់កាប់សម្លាប់ជាច្រើន, ហើយការជឿជាក់ នូវលទ្ធិសាសនា និងសច្ចធម៌ស្ថិតនៅក្នុងពិភពលោក កាន់តែតិចតួចស្តួចស្តើង ។ មហាក្សត្រិយ៍ប្រព្រឹត្តពាលទុច្ចរិតជាច្រើន; ពួកព្រាហ្មណ៍លុះក្នុងអំណាចមាតុគ្រាម, ស្វាមីចិត្តមិនត្រង់នឹងប្រពន្ធ, កូនស្អប់ឪពុក, មិត្តទៅជាសត្រូវ ។ ចូរអ្នកក្រឡេកមើល! មច្ចុរាជមិនបានអត់ទុនចំពោះអភិមន្យុ (Abhimanyu) ដែលមានមារខាងមាតានាមកិស្ណៈ ហើយមានបិតានាមអជ៌ុន (Arjuna), ហើយកាលណាព្រះយមរាជនាំយកមនុស្សទៅ ភោគទ្រព្យស្ថិតនៅទោលក្នុងគេហដ្ឋាន ហើយមាតាបិតា, ប្រពន្ធ កូន បងប្រុសនឹងញាតិសាលោហិត គ្មានប្រយោជន៍អ្វីសោះឡើយ ។ បុណ្យ, បាប, កម្មអាក្រក់, គុណធម៌តែងជូនដំណើរមនុស្សនោះ ហើយញាតិសាច់សន្តានក្នុងគ្រួសារនាំមនុស្សនោះយកទៅចូបដ្ឋានដើម្បីបូជា ។ អ្នកឃើញឬទេ! យប់បាត់ទៅ, ថ្ងៃមកដល់, ព្រះចន្ទលិចទៅ, ព្រះអាទិត្យរះឡើង ។ ដូចជាវ័យក្មេងទៅបាត់, វ័យ

ចាស់មកដល់ ៗ កាលវេលាអស់ទៅៗតែមនុស្សមិនអាចប្រព្រឹត្តល្អទៅបាន ៗ ប្តូរអ្នកមានគម្ពីរ "សត្យយុគ" (សម័យវិសេសមាន ៤.០០០ ឆ្នាំស្ថានសួគ៌, ក្នុងមួយឆ្នាំស្ថានសួគ៌មាន ៣៦០ ឆ្នាំស្ថានមនុស្សលោក ឬ ១.៤៤០.០០០ ឆ្នាំស្ថានមនុស្សលោក មានបុព្វណ្ហកាលជាបឋម គឺមុនចូលទៅក្នុងសម័យនេះ, ៤០០ ឆ្នាំស្ថានសួគ៌ (រាប់ជា ១៤.៤០០ ឆ្នាំស្ថានមនុស្សលោក) ហើយមានសាយណ្ហកាល ៤០០ ឆ្នាំស្ថានសួគ៌ជាអវសាន, តពីសម័យនេះ គឺ១៤.៤០០ ឆ្នាំស្ថានមនុស្សលោក. បើរាប់ទាំងអស់, សត្យយុគនេះមាន ១.៧២៨.០០០ ឆ្នាំស្ថានមនុស្សលោក, កំណត់ ៣៦០ថ្ងៃក្នុង ១ ឆ្នាំ) ៗ ក្នុងកាលនោះ មានបុរសម្នាក់នាម មន្ធាតៈ (Mandhata) ដែលបានសោយរាជ្យជាស្តេចមានព្រះកិត្តិនាមល្បីល្បាញ ហើយព្រះរាជកិត្យានុភាព បានឮរន្ទឺទៅពាសពេញពិភពលោក ហើយនៅក្នុងកាលដែលគេហៅថាត្រេតាយុគ (Trêta-Yug) កាលជាពលិកម្ម មាន ១.២៩៨.០០០ ឆ្នាំស្ថានមនុស្សលោក, មានព្រះរាជាមួយអង្គទ្រង់ព្រះនាមព្រះបាទស្រីរាមចន្ទ្រ (Çri-Râma Chandra) ទ្រង់បានកសាងស្ពានមួយឆ្លងកាត់មហាសាគរ ៗ ទ្រង់បានរុះរើនូវបន្ទាយធំសីលង់ ហើយពិឃាដរាវណៈ ៗ អ្នកជ្រាបទេ កាលនៅទ្វាបយុគ (Dvâpar-Yug) កាលជាវិចិកិច្ឆា,សង្ស័យមាន ៨៦៤.០០០ ឆ្នាំស្ថានមនុស្សលោក, មានមហារាជមួយអង្គទ្រង់ព្រះនាមយុធិស្ថិរ (Yudhisthir) បានសោយរាជ-

សម្បត្តិមានព្រះកិត្តិនាមល្បីល្បាញលុះសព្វថ្ងៃ ។ ព្រះមហាក្សត្រិយ៍ដែលមានបុញ្ញានុភាពបែបនេះ ក៏គង់កាលវេលាលេបយកព្រះជន្មាយុអស់ទៅ គ្មានគេបរួចសោះឡើយ ។

" កាលវេលាតែងលេបយកជីវិតសត្វបក្សាបក្សី នៅលើអាកាស. សត្វនៅក្នុងសមុទ្រ ហើយទុក្ខក៏តែងធ្លាក់ទៅលើសត្វទាំងនេះថែមទៀត ។ អ្នកណាដែលនៅលើផែនដីនេះ ក៏មិនអាចគេចឲ្យរួចផុតពីកាលវេលាសោះឡើយ ។ បើទុកជាខ្លួនមានចិត្តជាប់ស្អិតចង់រស់នៅលើផែនដីនេះ ក៏ជាអសារឥតការ ហើយត្រូវតែគោរពប្រតិបត្តិតាមទំនងនៃសាសនាទាំងឡាយ " ។

កាលលោកវិស្ណុសម៌ៈពោលរួចហើយ, គោវិន្ទព្រាហ្មណ៍ ក៏តាំងចិត្តថា " ត្រូវតែប្រព្រឹត្តនូវគុណធម៌ " ហើយមានប្រសាសន៍ទៅកាន់បុត្រាខ្លួនថា: " ក្នុងពេលដែលអញកំពុងអង្គុយធ្វើពលិកម្ម, ចូរឯងទៅឯសមុទ្រ ទៅរកអណ្តើកមួយមកឲ្យអញ " ។

បុត្រាបានទទួលបង្គាប់ហើយក៏ទៅរកអ្នកនេសាទត្រី ហើយពោលថា " ចូរអ្នកយកប្រាក់នេះហើយយកអណ្តើកមកឲ្យខ្ញុំមួយកុំខាន " ។ អ្នកនេសាទក៏យកប្រាក់នោះ ហើយក៏យកអណ្តើកមកឲ្យបុរសនោះ ។ កូនច្បងពោលទៅកាន់ប្អូនបន្ទាប់ថា: " ចូរប្អូនយកអណ្តើកនេះទៅឲ្យលោកឪពុក" ។ ប្អូនបន្ទាប់ប្រើទៅប្អូនពៅទៀត, តែប្អូនពៅមិនព្រមយក

ទៅ, ដោយពោលប្រកែកថា: "បានជាខ្ញុំមិនយកទៅ, ព្រោះដៃខ្ញុំកាលណាពាល់អណ្តើកមុខជាំជាប់ក្លិនស្អុយមកជាមួយផង ព្រោះខ្ញុំជាបុគ្គលរើសអើងម្ហូបអាហារ ។

ប្អូនបន្ទាប់ថា: ខ្ញុំជាបុគ្គលរើសអើងស្ត្រី ។

បងច្បងថា: ខ្ញុំជាបុគ្គលរើសអើងគ្រែ ។

ដល់ឈ្លោះគ្នាទៅវិញទៅមក, បុរសទាំងបីនាក់ក៏មិនបានយកអណ្តើកទៅជូនព្រាហ្មណ៍ជាបិតា, ហើយក៏ដើរទៅដល់មុខទ្វារព្រះបរមរាជវាំង, បង្គាប់ទៅនាយទ្វារបាលឲ្យទៅក្រាបទូលព្រះមហាក្សត្រិយ៍ថា មានព្រាហ្មណ៍បីនាក់មានរឿងរ៉ាវឈ្លោះគ្នា" ។

នាយឆ្មាំទ្វារក៏បានទៅក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ ។ ទ្រង់មានព្រះបន្ទូលឲ្យហៅព្រាហ្មណ៍ទាំងបីនាក់មកសួរថា "ហេតុម្តេចក៏បានជាអ្នកឯងទាស់ឈ្លោះគ្នា?" ។

ប្អូនពៅក្រាបបង្គំទូលថា: "ទូលបង្គំជាអ្នករើសអើងម្ហូបអាហារ ។

ប្អូនបន្ទាប់ក្រាបបង្គំទូលថា "បពិត្រព្រះភូមិន្ទ, ទូលបង្គំជាអ្នករើសអើងស្ត្រី" ។

បងបង្អស់ក្រាបបង្គំទូលថា: "បពិត្រព្រះធម្មិករាជ, ទូលបង្គំជាអ្នករើសអើងគ្រែដេក (ដំណេក)" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជឱង្ការថា: "ខ្ញុំនឹងពិសោធន៍មើលនូវការរើសអើងទាំងនេះឲ្យជាក់ស្តែង" ហើយទ្រង់ហៅនាយពិសេស មកបង្គាប់ឲ្យរៀបចំម្ហូបអាហារផ្សេង ៗ ដោយម៉ត់ចត់ ដើម្បីឲ្យដល់ព្រាហ្មណ៍ដែលជាអ្នករើសអើងអាហារ ។ នាយពិសេសក៏បានធ្វើម្ហូបអាហារជាក់ទាំងនោះយកមកជូនព្រាហ្មណ៍ តែដល់ព្រាហ្មណ៍បរិភោគម្ហូបនោះមួយម៉ាត់ទៅក៏យល់ថាម្ហូបនេះមានក្លិនស្អុយ ។ ព្រាហ្មណ៍ក៏ទុកម្ហូបនៅទីនោះ, លាងដៃស្អាតហើយទៅក្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍ ។ ទ្រង់មានព្រះបន្ទូលសួរថា "តើអ្នកឯងបានបរិភោគអាហារនោះមានទោសអ្វីទេ?" ។

ព្រាហ្មណ៍ក្រាបបង្គំទូលថា: "ម្ហូបនោះមានក្លិនស្អុយ, ទូលព្រះបង្គំមិនបានបរិភោគនូវម្ហូបនោះទេ" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជឱង្ការសួរថា: "តើក្លិនស្អុយនៃម្ហូបនោះមកពីហេតុអ្វី?" ។

ព្រាហ្មណ៍ថ្វាយបង្គំទូលថា: "បពិត្រមហារាជ, បាយនេះមកពីស្រូវដែលស្ទួននៅលើថ្នូបង្ហានចាស់, ហើយបាយនេះបញ្ចេញក្លិនសាកសពស្អុយពន់ពេក, បានជាទូលព្រះបង្គំបរិភោគមិនកើត" ។ ព្រះរាជាកាលទ្រង់ព្រះសណ្តាប់នូវពាក្យព្រាហ្មណ៍នោះហើយ ក៏ត្រាស់ហៅនាយពិសេសមកសួរថា "អង្ករដែលយកមកដាំបាយនេះបានមកពីភូមិណា?" ។

នាយពិសេសក្រាបបង្គំទូលថា: "បពិត្រមហារាជ, បាយនេះទូលព្រះបង្គំបានយកអង្ករពីភូមិសិវបុរ: (Çivapur) មកដាំ ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលឲ្យហៅអ្នកស្រែនៅភូមិនោះ មកជួបនឹងព្រះអង្គ ។ ដល់សាមិន្ទារ: (**Samindâr**, អ្នកកម្មសិទ្ធដី) មកចំពោះព្រះភក្ត្រព្រះរាជា ៗ ទ្រង់មានព្រះបន្ទូលសួរគហបតីនោះថា: "ស្រូវនោះដាំនៅលើដីឯណា ?" ។ គហបតីក្រាបបង្គំទូលថា: "បពិត្រមហារាជ, ស្រូវនេះដាំលើថូបដ្ឋាន" ។

ព្រះរាជាទ្រង់មានព្រះបន្ទូលនឹងព្រាហ្មណ៍នោះថា: "អ្នកឯងថាត្រូវមែន, អ្នកឯងជាអ្នកប៉ិនប្រសប់ខាងបរិភោគអាហារមែន" ។

រួចទ្រង់ត្រាស់បង្គាប់ឲ្យហៅអ្នកដែលរើសអើងស្ត្រី, ទ្រង់បានចាត់ឲ្យដាក់គ្រែមួយក្នុងបន្ទប់ព្រមទាំងវត្ថុទាំងឡាយ ជាគ្រឿងក្រេកក្រអាលសព្វគ្រប់, ទ្រង់ត្រាស់បង្គាប់ឲ្យហៅស្ត្រីមួយស្អាតប្រិមប្រិយ, មកដេកជាមួយបុរសនោះ ។ អ្នកទាំងពីរកំពុងដេកគ្នា, ព្រះមហាក្សត្រទ្រង់លាក់បំពួនព្រះអង្គ ហើយទ្រង់ព្រះនេត្រតាមប្រហោងជញ្ជាំងទតទៅឃើញព្រាហ្មណ៍នោះរៀបនឹងឱបស្ត្រីនោះ, ស្រាប់តែងាកក្បាលចេញ, ដល់គាត់បានហិតក្លិនមិនគប្បីដែលមកពីរន្ធដង្ហើមស្ត្រី ដកចេញចូលនោះ រួចគាត់ក៏និទ្រាលក់ទៅ ។

ព្រះពោធិសត្វទ្រង់បានជ្រាបនូវរឿងរ៉ាវទាំងនេះ; ទ្រង់ស្តេចយាងវិលត្រឡប់មកកាន់ព្រះបរមរាជវាំងវិញដើម្បីទឹងផ្ទុសម្រាកព្រះកាយ, ព្រឹកឡើងដល់ទ្រង់ស្តេចគង់នៅលើក្រឡាព្រះបន្ទំ, ទ្រង់ត្រាស់បង្គាប់ឲ្យហៅព្រាហ្មណ៍នោះមកគាល់ហើយសួរថា "តើព្រាហ្មណ៍ឯងពីយប់មិញ, បានដេកលក់សប្បាយត្រេកត្រអាលសុខស្រួលឬ"។ ព្រាហ្មណ៍ក៏ក្រាបបង្គំទូលថា: "បពិត្រមហារាជ, ទូលព្រះបង្គំឥតបានសប្បាយត្រេកត្រអាលទឹងស្ត្រីនេះសោះ ព្រោះស្ត្រីនេះមានខ្យល់អស្សាសៈបស្សាសៈដូចក្លិនពពែ ហើយចិត្តទូលបង្គំមិនប្រតិព័ទ្ធ"។

ព្រះនរបតីទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ព្រាហ្មណ៍ហើយ ទ្រង់ហៅស្ត្រីម្នាក់ដែលបានយកនារីនេះមកហើយទ្រង់មានព្រះបន្ទូលសួរថា "នារីនេះមកពីណា?"។ ស្ត្រីនោះក៏ក្រាបបង្គំទូលថា: "នារីនេះជាកូនស្រីបង្កើតខ្ញុំម្ចាស់។ កាលនាងនេះមានជន្មាយុ ៣ ខែ មាតាក៏អនិច្ចកម្មទៅ។ ខ្ញុំម្ចាស់ក៏ឲ្យទឹកដោះពពែពៅ ហើយខ្ញុំម្ចាស់ថែទាំរក្សាតមក"។

ព្រះពោធិសត្វទ្រង់ព្រះសណ្តាប់ដូចនោះហើយ, ទ្រង់មានព្រះបន្ទូលទៅកាន់ព្រាហ្មណ៍នោះថា: "មែនហើយ, អ្នកឯងជាអ្នកចេះដឹងជ្រៅជ្រះខាងស្ត្រីពិតមែន"។

រួចទ្រង់បានបញ្ជាឲ្យគេយកពូកជាច្រើនផ្ទត់មកក្រាលលើគ្រែ, ហើយទ្រង់ត្រាស់បង្គាប់ឲ្យអ្នកដែលរើសអើងគ្រែ, និទ្រាលើពូកនោះទៅ។

ដល់ព្រឹកស្អែក ទ្រង់បានត្រាស់បង្គាប់ឲ្យហៅបុរសនេះមកហើយទ្រង់មានព្រះបន្ទូលសួរថា "អ្នកឯងដេកលក់ស្រួលទេយប់មិញ?" ។

បុរសនោះក្រាបបង្គំទូលថា: "បពិត្រមហារាជ ទូលបង្គំទទួលទានដំណេកឥតលក់សោះយប់មិញ" ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលសួរតទៅទៀតថា: "ព្រោះហេតុអ្វី?" ។ បុរសនោះក៏ក្រាបបង្គំទូលថា: "បពិត្រមហារាជ នៅផ្នត់ពូកទី ៧ មានពេមមួយបាក់ខ្នងទូលបង្គំ, ហើយទូលបង្គំទទួលទានដំណេកមិនបានសោះ" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្តាប់. ទ្រង់ទតនូវផ្នត់ពូកទី ៧ ឃើញមានពេមមួយមែន ហើយទ្រង់មានព្រះបន្ទូលទៅកាន់ព្រាហ្មណ៍នោះថា: "ឯងជាអ្នកបះដើងពិតប្រាកដខាងគ្រែដេកមែន" ។

ដល់អារក្សបានក្រាបបង្គំទូលព្រះមហាក្សត្រិយ៍សព្វគ្រប់, ក៏ទូលសួរទ្រង់ថា: "បណ្តាអ្នកទាំងបី, តើអ្នកណាប៉ុនប្រសប់ជាងគេ?" ។

ព្រះបាទពិរ-ពិក្រមាជិត ទ្រង់មានព្រះបន្ទូលតបថា: អ្នកក្រោយបង្អស់ ។

អារក្សដល់បានឮព្រះរាជឧត្តរព្រះមហាក្សត្រិយ៍ ក៏វិលត្រឡប់ទៅកាន់រុក្ខជាតិវិញ, ព្រះរាជាទ្រង់ក៏មកយកអារក្សនោះ ចងជាប់លើព្រះអង្គនាំយកទៅ ។

ចប់រឿងទី ២៣ នៅមានរឿងទី ២៤ តទៅទៀត ។

# រឿងចិញ្ចៀនទិព្យ

## អ្នកស្រីសារីយ៉ាន់ ប្រែពីបារាំងមកជាខ្មែរ

(តមក)

---

ព្រះស្នំតបថា "ម្ចាស់ក្សត្រី! យើងយកថ្នាំពុលបន្តិចដាក់ក្នុងទឹកថ្វាយស្ដេចសោយ លុះទ្រង់សោយស្រេចកាលណា ព្រះអង្គមុខជានឹងសន្ធប់" ។ ព្រះនាងនឹងស្រីស្នំធ្វើតាមដែលបានគិតគ្នា មិនយូរប៉ុន្មាន ព្រះមហាក្សត្រដោកសន្ធប់ទៅ ព្រះនាងហូតយកចិញ្ចៀនពីម្រាមព្រះហស្ដព្រះអង្គហើយមានព្រះបន្ទូលថា: "មាដិនា! ខ្ញុំចង់ដោះខ្លួនឲ្យរួចអំពីអំណាចព្រះមហាក្សត្រនេះ ដ្បិតខ្ញុំមិនចង់មើលព្រះភក្ត្រទ្រង់សោះ" ។ ស្នំទូលតបថា: "បើដូច្នេះ ចូរព្រះនាងបង្គាប់អារក្សជាបំរើនៃចិញ្ចៀននេះឲ្យនាំយកស្ដេចនេះទៅឯនគរស្ដេចវិញទៅ ព្រះនាងនឹងបានរួចពីព្រះអង្គហើយ" ។

ព្រះនាងដាក់ចិញ្ចៀនទៅដីដោយមានវាចាថា: "សូមឲ្យអារក្សដែលនៅរក្សាចិញ្ចៀននេះ ចេញមក" ។ មៃមូនបង្ហាញខ្លួនឲ្យឃើញភ្លាម វន្ទាព្រះនាងហើយនិយាយថា: "បើព្រះជាម្ចាស់លោកប្រោសប្រណីព្រះនាងដូច្នេះហើយ សូមព្រះនាងត្រាស់បង្គាប់មកចុះ" ។ – ចូរយកអាមនុស្សកំណាចនេះទៅចោលឯស្រុកវាវិញទៅ ។ មៃមូនត្រកងស្ដេចហោះឡើងហើយយកទៅទម្លាក់ចោលនៅប្របមាត់ទ្វារក្រុង ។

លុះព្រលឹមឡើងគេមកបើកទ្វារ គេឃើញរូបព្រះអង្គល្អដូចជាព្រះច័ន្ទពេញបូណ៌មី ។ អ្នកស្រុកឃើញហេតុដូច្នេះហើយឆោឡោឡើង ទៅទូលព្រះមហាក្សត្រថា: "ព្រះអង្គម្ចាស់អាលីដែលជាព្រះអនុជរបស់ទ្រង់ ឥឡូវផ្ទុំនៅស្តុកស្តិនក្បែរមាត់ទ្វារក្រុងឯណោះ' ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយក៏ឡើងគង់សេះប្រញាប់ទៅទីនោះ ទ្រង់បង្គាប់ឲ្យលើកព្រះអនុជយកទៅព្រះបរមរាជវាំង ទ្រង់ហៅពេទ្យហ្លួងមកពិនិត្យក្រែងមានជម្ងឺអ្វី ប៉ុន្តែគេមិនឃើញមានអ្វីសោះ គ្រូពេទ្យក៏បង្គាប់ឲ្យយកទឹកខ្ទះមកចាក់លើព្រះកេសព្រះអង្គម្ចាស់អាលី ៗ ភ្ញាក់ព្រះអង្គឡើង ទ្រង់បង្ហូរទឹកថ្នាំពុលមកវិញ ហើយស្រែកថា: 'មាជិទា" ។ ព្រះករុណាទ្រង់ព្រះសំរួលហើយមានព្រះបន្ទូលថា "ចុះរឿងហេតុអ្វីបានជាដល់ម្ល៉េះប្អូន! មានរឿងរ៉ាវយ៉ាងណាខ្លះ?" ។ ព្រះអង្គម្ចាស់អាលីដឹងខ្លួនឡើង ទ្រង់ព្រះកន្សែងជាខ្លាំងហើយឱបព្រះរាម ទើបទ្រង់ទូលព្រះរាមថា: "ក្រាបទូលព្រះរាម! គេលួចយកចំពៀនរបស់ទូលព្រះបង្គំជាខ្ញុំដោយប្រើកលឧបាយបញ្ឆោត" ។ ព្រះរាមទាំងពីរក៏សួរទៀតថា "តើគេធ្វើកលបញ្ឆោតយ៉ាងណា?" ។ ព្រះអង្គម្ចាស់អាលីមានព្រះបន្ទូលរៀបរាប់រឿងរ៉ាវតាំងតែពីដើមដល់ចប់ថ្វាយព្រះរាមទ្រង់ព្រះសណ្ដាប់ ។

— តើប្អូនគិតធ្វើយ៉ាងណា បើដូច្នេះ? ។

— ទូលព្រះបង្គំជាខ្ញុំនឹងទៅតាមរកចំពៀននោះវិញ លុះត្រាតែមរណភាពមកដល់ ទើបទូលព្រះបង្គំឈប់ ។

– កុំទៅតាមផ្ញើអ្វី នៅជាមួយនឹងយើងបានហើយ ។

– ពុទ្ធោ! ទូលព្រះបង្គំត្រូវតែទៅខានពុំបានទេ ។

ព្រះអង្គម្ចាស់កាលីបានយាងទៅកាន់ព្រះដំណាក់ដើមវិញ ។ ពួកអ្នកបំរើឃើញព្រះអង្គត្រឡប់មកវិញ ដោយសេចក្ដីសុខសប្បាយដូច្នោះ ក៏នាំគ្នាលេងសប្បាយរីករាយ ហើយសរសើរដល់ក័ព្ទសំណាងល្អនៃព្រះអង្គ ។ ទ្រង់ក៏ដោះលែងពួកអ្នកបំរើ ពួកខ្ញុំកម្ដរទោៗ ព្រមទាំងព្រះរាជទានទ្រព្យផ្សេងៗផង ។

ក្រោយនោះព្រះអង្គម្ចាស់កាលីយកព្រះរាជទ្រព្យចំនួន ៥០ ពាន់ឌីណា ទ្រង់ឡើងគង់សេះមួយយ៉ាងចំណាន ទៅក្រាបបង្គំលាព្រះរាមទាំងពីរ ហើយក៏ស្ដេចឆ្ពោះដំរង់ទៅអៀក់ៗ ទ្រង់ចូលទៅដល់បាងដាត ទ្រង់ចុះទៅបាស្រាហ៍ ទ្រង់លក់សេះហើយស្ដេចដម្រង់ទៅមាត់សមុទ្រដើម្បីនឹងឆ្ពោះទៅកាន់កោះ អែលកាហ្វូរ ទ្រង់ប្រទះសំពៅមួយរៀបនឹងចេញ ទ្រង់ទិញសំបុត្រស្រេចក៏ឡើងគង់ទៅ ។

ជួនជាមានដំណើរល្អណាស់ ទ្រង់សោយក្រយាស្ងោយនឹងសោយទឹកស្រវឹងជាមួយនឹងពួកនាវិក ហើយប្រស្រ័យគ្នាលេងយ៉ាងស្និទ្ធស្នាល, កំពុងតែលេងសើចសប្បាយ ស្រាប់តែសំពៅទៅដល់កោះអែល អង់បារ ដែលនៅពាក់កណ្ដាលផ្លូវ ។ នៅពេលនោះ មានមនុស្ស ២០០ នាក់ ឡើងមកលើសំពៅ ។ វរនារីឯកដើរចូលទៅជិតហើយសួរថា: "សូម

លោកមានប្រសាសន៍មកមើល! លោកមានការអ្វី?" ។ ទាហានម្នាក់ឆ្លើយថា: "ចូរតាប្រាប់ថា: ព្រះរាជិនី យ៉ាគូតាហ៍ ដែលគង់នៅឯកោះ មែល-កាហ្វូរ បានផ្ញើសារមួយមកថ្វាយស្ដេចកោះនេះថា: បើមានអ្នកដំណើរមកពីអៀហ៍ក សូមទ្រង់កុំលែងឲ្យទៅ មុននឹងបានពិនិត្យមើលលក្ខណៈដូចតទៅនេះ: បើទ្រង់បានឃើញបុរសម្នាក់ក្មេង គ្មានពុកមាត់ សម្បុរស មុខល្អមានសក់វែង មានប្រជ្រុយមួយនៅថ្ពាល់ខាងស្ដាំ មានប្រជ្រុយមួយទៀតធំនៅស្មាខាងស្ដាំ សូមព្រះអង្គនាំយកមកឲ្យយើងៗ នឹងសម្លាប់ចោល" ។ លោកវរនារីឯកឆ្លើយតបថា "យើងគ្មានមនុស្សណាមានលក្ខណៈដូចនេះទេ" ។ ទាហានតបថា "ព្រះមហាក្សត្រកោះនេះ ទ្រង់បង្គាប់ឲ្យសំពៅចូលមកក្បែរច្រាំងដើម្បីពិនិត្យមើលម្នាក់ម្ដងៗ បើសិនជាគ្មានមនុស្សកិនភាគបែបនេះនៅលើនាវានេះទេ សូមឲ្យព្រះដ៏មានបុណ្យជួយថែរក្សា" ។ លោកវរនារីឯកត្រឡប់ចូលក្នុងសំពៅហើយប្រាប់ពួកពាណិជថា "ចូរអ្នកដឹងថា បុរសម្នាក់ដែលនៅក្នុងកប៉ាល់ជាមួយនឹងយើង ជាមនុស្សដែលគេកំពុងតែរកចាប់ តើអ្នកគិតធ្វើដូចម្ដេច?" ។ តាចាស់ម្នាក់ដែលមានប្រាជ្ញាឆ្លាតជាងគេឆ្លើយថា: "ព្រះអើយ! កិច្ចការនេះនាំឲ្យយើងឃើញហេតុពីរយ៉ាង: ១ យ៉ាងមានអត្ថប្រយោជន៍ ១ យ៉ាងទៀតនាំឲ្យយើងវិនាស" ។

(អានត)

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## បរិយាយពីពាក្យ " វរ្ម័ន "

## លោក បាប-ពិន រៀបរៀង

---

ក្នុងនាមនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ខ្ញុំសូមបរិយាយនូវបទពិចារណា ព្រះរាជពង្សាវតារខ្មែរ ចំពោះពាក្យ " វរ្ម័ន " ដែលជាព្រះនាមនៃព្រះមហាក្សត្រិយ៍ខ្មែរយើង សម័យអតីត និងសម័យបច្ចុប្បន្ន ដូចតទៅនេះ:

ប្រវត្តិសាស្ត្រខ្មែរ បានបញ្ជាក់ថា: ប្រទេសខ្មែរយើងសម័យអង្គរ មានព្រះមហាក្សត្រិយ៍ដែលមានចុងព្រះនាម " វរ្ម័ន ៗ " ជាច្រើនព្រះអង្គ, សម័យឯទៀត ៗ មានសម័យលង្វែកសម័យឧត្តុង្គជាដើម គ្មានទេ; លុះដល់មកសម័យភ្នំពេញទើបមានឡើងវិញ គឺព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម-សីហនុ វរ្ម័ន ជាម្ចាស់ផែនដីប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ, ដែលជាបញ្ហាគួរឲ្យអ្នកប្រវត្តិសាស្ត្រសន្និដ្ឋានជាបទពិចារណាព្រះរាជពង្សាវតារខ្មែរ ដូចខ្ញុំនឹងអធិប្បាយជូនទៅខាងមុខ ៗ

ពាក្យ " វរ្ម័ន " ជានាមស័ព្ទ ភាសាសំស្ក្រឹត, វចនានុក្រមខ្មែរ ប្រែថា " ក្រោះ " គឺគ្រឿងក្រោះធ្វើពីដែក ឬពាសដែក ជាគ្រឿងសឹក គ្រឿងចម្បាំង មានអាវក្រោះ រថក្រោះជាដើម; បើជានាមមនុស្ស ដូច

ព្រះនាមព្រះមហាក្សត្រខ្មែរយើងសម័យអង្គរ មានព្រះនាម "ជយវរ្ម័ន" ជាដើម ប្រែថា "ព្រះរាជាទ្រង់គ្រឿងក្រោះប្អារក្រោះមានជ័យ" ។

ព្រះមហាក្សត្រខ្មែរយើងសម័យអង្គរ ដែលមានព្រះនាម "វរ្ម័ន ៗ" មាន ៣២ ព្រះអង្គ សឹងមានប្រាកដក្នុងសិលាចារិកខ្មែរ ដែលលោកអាចារ្យ ប៉ាង-ខាត់ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ បានស្រង់មករៀបរៀងជាសៀវភៅ "មគ្គុទ្ទេសក៍នគរ" ដូចរាយព្រះនាមតទៅនេះ គឺ

១ - ព្រះភវវរ្ម័នទី ១ រាជ្យ ព.ស. ១០៩៣
២ - ព្រះមហេន្ទ្រវរ្ម័ន -ដ- ១១៤៣
៣ - ព្រះឦសានវរ្ម័នទី ១ -ដ- ១១៥៩, ១១៦៩
៤ - ព្រះភវវរ្ម័នទី ២ -ដ- ១១៨២
៥ - ព្រះជយវរ្ម័នទី ១ -ដ- ១២០០, ១២១៧
៦ - ព្រះជយវរ្ម័នទី ២ -ដ- ១៣៤៥, ១៣៩៧
៧ - ព្រះជយវរ្ម័នទី ៣ -ដ- ១៣៩៧, ១៤២០
៨ - ព្រះឥន្ទ្រវរ្ម័នទី ១ -ដ- ១៤២០, ១៤៣២
៩ - ព្រះយសោវរ្ម័នទី ១ -ដ- ១៤៣២, ១៤៥៣
១០ - ព្រះហរ្សវរ្ម័នទី ១ -ដ- ១៤៥៣, ១៤៦៥
១១ - ព្រះឦសានវរ្ម័នទី ២ -ដ- ១៤៦៨

| | | | |
|---|---|---|---|
| ១២ - | ព្រះជយវរ្ម័នទី ៤ | រាជ ព. ស. | ១៤៦៤, ១៤៨៥ |
| ១៣ - | ព្រះហរ្សវរ្ម័នទី ២ | - ដ - | ១៤៨៥, ១៤៨៧ |
| ១៤ - | ព្រះរាជេន្ទ្រវរ្ម័នទី ២ | - ដ - | ១៤៨៧, ១៥១១ |
| ១៥ - | ព្រះជ័យវរ្ម័នទី ៥ | - ដ - | ១៥១១-១៥៤៤ |
| ១៦ - | ព្រះឧទយាទិត្យវរ្ម័នទី ១ | - ដ - | ១៥៤៤, ១៥៤៥ |
| ១៧ - | ព្រះជយវីរវរ្ម័ន | - ដ - | ១៥៤៥, ១៥៥៣ |
| ១៨ - | ព្រះសូរ្យវរ្ម័នទី ១ | - ដ - | ១៥៥៤, ១៥៩២ |
| ១៩ - | ព្រះឧទយាទិត្យវរ្ម័នទី ២ | - ដ - | ១៥៩២, ១៦០៩ |
| ២០ - | ព្រះហរ្សវរ្ម័នទី ៣ | - ដ - | ១៦០៩, ១៦៣៣ |
| ២១ - | ព្រះជយវរ្ម័នទី ៦ | - ដ - | ១៦២៥, ១៦៥០ |
| ២២ - | ព្រះធរណិន្ទ្រវរ្ម័នទី ១ | - ដ - | ១៦៥០, ១៦៥៦ |
| ២៣ - | ព្រះសូរ្យវរ្ម័នទី ២ | - ដ - | ១៦៥៦, ១៦៧៨ |
| ២៤ - | ព្រះធរណិន្ទ្រវរ្ម័នទី ២ | - ដ - | ១៦៩៣ |
| ២៥ | ព្រះយសោវរ្ម័នទី ២ | - ដ - | ១៧០៣ |
| ២៦ - | ព្រះត្រិភុវនាទិត្យវរ្ម័ន | - ដ - | ១៧០៨, ១៧២០ |
| ២៧ - | ព្រះជយវរ្ម័នទី ៧ | - ដ - | ១៧២៤, ១៧៤៤ - |
| ២៨ - | ព្រះឥន្ទ្រវរ្ម័នទី ២ | - ដ - | ១៧៤៤, ១៧៨៦ |
| ២៩ - | ព្រះជយវរ្ម័នទី ៨ | - ដ - | ១៧៨៦, ១៨៣៨ |

៣០ - ព្រះស្រីន្ទ្រវរ្ម័ន រវាង ព. ស. ១៨៣៨, ១៨៥០ .

៣១ - ព្រះស្រីន្ទ្រជយវរ្ម័ន -ដ- ១៨៥០, ១៨៧០

៣២ - ព្រះជយវរ្ម័ទិបរមេស្វរ. -ដ- ១៨៧០[១]

ប្រាសាទថ្មនៅទីអង្គរទាំងប៉ុន្មាន គឺជាស្នាព្រះហស្តព្រះមហាក្សត្រខ្មែរ ព្រះនាម "វរ្ម័ន" ទ្រង់សាងទុកជាព្រះកេរ្តិ៍ ដូចសាកលលោកបានឃើញច្បាស់ស្រាប់ហើយ ។

បណ្តាព្រះមហាក្សត្រព្រះនាម "វរ្ម័ន" ទាំង ៣២ ព្រះអង្គនោះ សូមស្រង់យកចំពោះតែព្រះរាជប្រវត្តិព្រះបាទជយវរ្ម័នទី ៧ មកថ្លែងដោយសង្ខេប ព្រោះព្រះរាជាអង្គនេះ ជាវីរៈក្សត្រទ្រង់ប្រកបដោយព្រះមហាតេជានុភាពច្រើន ទ្រង់ប្រតិបត្តិទសពិធរាជធម៌ ទ្រង់ធ្វើឧត្តមប្រយោជន៍ទុកព្រះកេរ្តិ៍ឲ្យខ្មែរជាន់ក្រោយច្រើនជាងព្រះមហាក្សត្រ ព្រះនាម "វរ្ម័ន" អង្គឯទៀត ៗ សឹងមានគន្ធបុល្លិ៍តាំងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ដែលលោក ល្វី-ហ្វីណូត៍ អតីតចាងហ្វាងសាលានេះ ជាអ្នកស្រាវជ្រាវរកសិលាចារឹកខ្មែរ បានសរសេរចារឹកភាសាសំស្ក្រឹត ១ មានសេចក្តីថា:

" សិលាចារឹកព្រះបាទជយវរ្ម័នទី ៧ ។ល។ បញ្ជាក់ពីជ័យជំនះពី
"អំពើព្រះរាជកុសលរបស់ព្រះអង្គ គឺទ្រង់កសាងមន្ទីរពេទ្យជាដើម ។ល។
" សិលាចារឹកទាំងនោះ បានព្រោលចំភ្លឺពង្សាវតារប្រទេសកម្ពុជាក្នុង

១ តាំងពីរជ្ជកាលទី ១ មកទល់នឹងរជ្ជកាលទី ៣២ រវាង ៨០០ ឆ្នាំ ។

"អតីតកាលឲ្យឃើញច្បាស់ថា ព្រះបាទជ័យវរ្ម័នទី ៧ ជាមហាកដា-
"ធិរាជ ១ ព្រះអង្គទ្រង់ប្រកបដោយធម៌ ។ល។ ព្រះរាជាអង្គនេះជា
"ក្សត្រសឹក (ក្សត្រចម្បាំង) មានជ័យជំនះជាប, ជារដ្ឋបុរស មាន
"ប្រសាសនោបាយខាងការបម្រើន, ទ្រង់សាងប្រទេសខ្មែរឲ្យរុងរឿង
ឥតមានព្រះរាជាអង្គណាក្នុងសម័យអង្គរស្មើនឹងព្រះអង្គបាន" ។

ចំណែកលោក សឺដែស អតីតចាងហ្វាងសាលាបារាំងសែសនៅចុង
បូព៌ាប្រទេស ជាអ្នកស្រាវជ្រាវរកសិលាចារិកខ្មែរ បានរៀបរៀង
សៀវភៅ ១ ឈ្មោះ "ជ័យវរ្ម័នទី ៧" មានសេចក្ដីដូចស្រង់មកដោយ
បំព្រួញ តទៅនេះថា:

"ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់ប្រសូតក្នុងរវាង គ. ស. ១១២០ ឬបើ
"យ៉ាងក្រោយណាស់ក្នុង គ. ស. ១១២៥ ជាព្រះរាជបុត្រព្រះបាទធរ-
"ណេន្ទ្រវរ្ម័នទី ២ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២, ត្រូវជាព្រះអនុជ
"រួមព្រះអយ្យិកាទឹងព្រះបាទសូរ្យវរ្ម័នទី ២ ដែលទ្រង់បានសាងប្រាសាទ
"នគរវត្ត ។ល។ ទ្រង់ព្រះទីវង្គតប្រហែលនៅ គ. ស. ១២០១ (១) ។

"ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានសាងប្រទេសកម្ពុជា (ឲ្យជា
"ប្រទេសមហាអំណាចនៅជ្រោយសុវណ្ណភូមិ) ក្នុងរជ្ជកាលរបស់ទ្រង់
ដ៏ខ្លី គឺមិនយូរហួសកំណត់ ២០ ឆ្នាំ" ។

---

១ ព្រះជន្ម ៨១ ព្រះវស្សា ។

" នៅលើជញ្ជាំងប្រាសាទបាយ័ននិងបន្ទាយឆ្មារ   គេឃើញមាន
" ឆ្លាក់ព្រះរូបព្រះបាទជយវរ្ម័នទី ៧ ត្រង់កាលដែលទ្រង់ចេញធ្វើសង្គ្រាម
" ជើងទឹកតនឹងពួកចាមដោយកងទ័ពទូក   ទ្រង់ព្រះសណ្ឋិតកាន់អាវុធ
" កណ្តាលទូកចម្បាំង  មានកងពលអុំចែវនិងកាន់អាវុធហែព្រះអង្គផង
" ជាចម្បាំងលើកប្រទេសកម្ពុជាឲ្យផុតស្រឡះពីខ្មាំងសត្រូវ  ។  ចម្លាក់
" នេះសសេចក្តីឲ្យឃើញថា   ប្រទេសខ្មែរសម័យបុរាណធ្លាប់មានកងទ័ព
" ជើងទឹកជើងគោក  យ៉ាងជំនាញ "  ។

" គេទុកព្រះរាជាអង្គនេះ  ជាស្តេចធំបំផុតដែលទ្រង់បានពង្រីកព្រះ
" រាជអាណាចក្រខ្មែរឲ្យធំទូលាយ  ( ជាងសព្វថ្ងៃនេះច្រើនភាគ ) ។ល។

" សិលាចារឹក ១២ កន្លែង  ជាសិលាចារឹកប្រកាសមន្ទីរពេទ្យ  មាន
" សេចក្តីដូចគ្នាទាំងអស់ថា: ព្រះបាទជយវរ្ម័នទី៧ទ្រង់មានព្រះរាជហឫទ័យ
" ជាបុណ្យ ទ្រង់ប្រឈួនដោយជម្ងឺបណ្តារាស្ត្រ ជាងប្រឈួនដោយព្រះ
" រោគផ្ទាល់ព្រះអង្គ  ។  នេះជាព្រះឆន្ទៈដ៏សំខាន់ក្នុងអារ្យធម៌និងក្នុងផែន
" ការគ្រប់គ្រងប្រទេសរបស់ព្រះមហាក្សត្រអគ្គប្រមុខរដ្ឋខ្មែរ   ដែលត្រូវ
" ទទួលខុសត្រូវក្នុងសេចក្តីសុខរបស់ប្រជារាស្ត្រ  ។  ព្រះបាទជយវរ្ម័ន
" ទី ៧ ទ្រង់បានសាងមន្ទីរពេទ្យ ១០២ កន្លែង   ក្នុងទិសទាំង ៤ នៃព្រះ
" នគរជាខាងក្រៅទីក្រុង     មានមន្ទីរពេទ្យនៅក្នុងក្រុងធំៗ សំខាន់ជាង
" នេះទៀត  គឺនៅទីអង្គរជាដើម "  ។

" ព្រះរាជធានីខ្មែរសម័យនោះឈ្មោះ " យសោធរបុរៈ " ព្រះបាទ
" ជយវរ្ម័នទី ៧ ទ្រង់រៀបចំដួសដុលជាថ្មីឲ្យល្អជាងដើម ទ្រង់បានសាង
" ទីក្រុងថ្មីៗទៀត មានទាំងប្រាសាទចាស់ដែលសាងពីមុនៗ ក្នុងកំពែង
" ក្រុងថ្មីនោះផង, ប៉ុន្តែដែលសំខាន់ជាងគេ គឺទ្រង់សាងនគរធំព្រមទាំង
" កំពែងចំនួន ១៤ គីឡូម៉ែត្រព័ទ្ធជុំវិញ និងប្រាសាទនៅកណ្ដាលគឺប្រាំ-
" សាទបាយ័ន - តាព្រហ្ម - បន្ទាយក្ដី - ព្រះខាន់ - នាគព័ន្ធ - តាសោម - តា-
" នៃបន្ទាយឆ្មារ ជាដើម សុទ្ធតែជាការថ្មីទាំងអស់ ៗ ឥតមានស្ដេច
" ស្រុកណាមួយ អាចធ្វើឲ្យរញ្ជួយឲ្យក្រមើកដូចព្រះមហាក្សត្រអង្គនេះ
" ឡើយ ៗ ល ៗ ៗ ល ៗ

សូមស្ទេះព្រះរាជប្រវត្តិព្រះមហាក្សត្រ ព្រះនាមវរ្ម័នសម័យអង្គរ
ត្រឹមប៉ុណ្ណោះ, ហើយសូមបរិយាយអំពីព្រះរាជប្រវត្តិ នៃព្រះមហាក្សត្រ
ព្រះនាមវរ្ម័នសម័យបច្ចុប្បន្ននេះដោយសង្ខេបតទៅ :

ប្រទេសកម្ពុជាបានប្រាសនិកសពាកព្រះមហាក្សត្រខ្មែរព្រះនាមវរ្ម័ន
រាង ៥០០ រយឆ្នាំទៅហើយ, លុះមកដល់សម័យកុំពេញ ក្នុងរដ្ឋកាល
បច្ចុប្បន្ននេះ ទើបមានឡើងវិញ គឺព្រះករុណា ព្រះបាទសម្ដេចព្រះ
នរោត្តម - សីហនុ វរ្ម័ន ព្រះចៅប្រទេសកម្ពុជាជាអម្ចាស់ជីវិតលើត្បូង
របស់យើងសព្វថ្ងៃនេះ ៗ

ព្រះប្រិយមហាក្សត្រអង្គនេះ គឺជាព្រះមហាក្សត្រតំណព្រះរាជវង្ស វរ្ម័នសម័យអង្គរដោយព្រះបរមនាមផង ដោយព្រះគុណសម្បត្តិផង ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ សូមព្រះរាជទានព្រះបរមរាជានុញ្ញាតប្រកាសបរិយាយអំពីព្រះបរមនាម និងព្រះគុណសម្បត្តិនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដូចតទៅនេះ :

ព្រះបរមនាមនៃព្រះប្រិយមហាក្សត្រ ព្រះចៅប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ ចែកជា ៣បទ គឺ ១- ព្រះនរោត្តម ២- ព្រះសីហនុ ៣- ព្រះវរ្ម័ន ។

១ – ព្រះបរមនាម " នរោត្តម " ជាព្រះគោត្តនាម ដែលសន្តតាមព្រះនាមព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម ( ព្រះសុវណ្ណកោដ្ឋ ) ជាព្រះរាជអយ្យកោទួតនៃព្រះអង្គ ។

២ – ព្រះបរមនាម " សីហនុ " ជាព្រះនាមដើម ដែលសម្តេចព្រះបរមរាជបិតា និងសម្តេចព្រះបរមរាជជននីនាថ ថ្វាយព្រះរាជទាន កាលព្រះអង្គប្រសូតមក, ដូចនឹងព្រះនាមព្រះបាទ " សីហហនុ " ជាព្រះរាជអយ្យកោព្រះសម្មាសម្ពុទ្ធ ( សមណគោតម ) បរមគ្រូយើង, តែលុបតួ " ហ " ១ ចេញ ដើម្បីស្រួលអាន ។

៣ – ព្រះបរមនាម " វរ្ម័ន " ជាព្រះនាមដែលថ្វាយកាលព្រះអង្គឡើងសោយរាជសម្បត្តិគ្រប់គ្រងព្រះរាជអាណាចក្រកម្ពុជា, ដូចនឹងព្រះនាមព្រះមហាក្សត្រ ព្រះនាមវរ្ម័នសម័យអង្គរ មានព្រះបាទជយវរ្ម័នទី ៧ ជាដើម ដែលជាក្សត្រសឹកដ៏ពូកែ ។

ព្រះបរមនាម "ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម-សីហនុវរ្ម័ន" ប្រែថា "ព្រះរាជាដ៏ឧត្តមជាងប្រជាជន ទ្រង់ត្រេកត្រអាលផ្ទះ ជាត្រើងសឹក ដ៏មានព្រះមហិទ្ធិរិទ្ធិដូចរាជសីហ៍" ។

ព្រះរាជករណីយកិច្ច នៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង របស់យើងសព្វថ្ងៃនេះមានបរិយាយជា ២ ប្រការ គឺ

១ - ព្រះអង្គមានព្រះរាជឆន្ទៈស្មោះស្ម័គ្រចំពោះព្រះពុទ្ធសាសនាជាអគ្គពុទ្ធសាសនូបត្ថម្ភកៈ ដល់ឋានៈខ្ពស់បំផុត គឺទ្រង់ធ្វើយកព្រះរាជ-ឧកាសក្នុងរាជ្យទ្រង់ព្រះផ្នួស ១ ព្រះវស្សាជាដើម ជាព្រះរាជាដ៏ធ្វើមពិបាករកព្រះរាជាអង្គណាមកប្រៀបផ្ទឹមឲ្យត្រឹមស្មើបាន, ទ្រង់ប្រព្រឹត្តទសពិធរាជធម៌, ទ្រង់ធ្វើព្រះរាជករណីយកិច្ចអ្វីៗ សុទ្ធតែប្រកបដោយធម៌ទាំងអស់, ទោះបីព្រះអង្គខ្វះព្រះរាជទ្រព្យយ៉ាងណាក៏ពុំទ្រង់រវល់ ថែមទាំងទ្រង់លះបង់សិរីរាជសុខក្នុងរាជសម្បត្តិដែលជាសុខុមាលសុខផងទៀត ទ្រង់លះបង់សេចក្ដីសប្បាយនានាជាកាមារម្មណ៍ ទ្រង់ស៊ូទ្រាំលំបាកព្រះអង្គ ដោយទ្រង់ព្រះព្យាយាមធ្វើព្រះរាជបេសកកម្មបម្រើប្រទេសជាតិមាតុភូមិ ដូចយើងបានដឹងឮឃើញច្បាស់ក្នុងគ្រានេះ ។ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បានត្រាទុកព្រះអង្គជាព្រះមហាក្សត្រដ៏ទ្រង់លះបង់នូវព្រះរាជអត្តសុខចំពោះព្រះអង្គ ទ្រង់ដូរយកជាតិសុខចំពោះប្រទេសជាតិទាំងមូល, ពោលដោយសង្ខេប គឺថាព្រះអង្គលះបង់សុខខ្លួន, ទ្រង់ដូរយកសុខ

វែងឆ្ងាយ. គួរឲ្យយើងទាំងឡាយស្ងើចព្រះរាជកិច្ចការបារមីនៃព្រះអង្គពន់ពេក;

២ – ព្រះអង្គមានព្រះរាជឆន្ទៈស្វាម៉ីភក្តិចំពោះប្រទេសជាតិ, ទ្រង់ព្រះព្យាយាមកសាងឧត្តមប្រយោជន៍ច្រើនយ៉ាងសម្រាប់ប្រទេស តាមលំនាំព្រះមហាក្សត្រខ្មែរព្រះនាមវរ្ម័ន ជំនាន់មហានគរ មានទ្រង់ផ្តើមសាងនិងទ្រង់ទំនុកបម្រុងវិទ្យាល័យព្រះស៊ីហនុ នៅក្រុងកំពង់ចាម ព្រមទាំងទ្រង់ទំនុកបម្រុងអ្នករៀនសូត្រ ហើយនិងមន្ទីរពេទ្យព្រះស៊ីហនុ នៅក្រុងភ្នំពេញព្រមទាំងទ្រង់ទំនុកបម្រុងអ្នកជម្ងឺជាដើម, ទ្រង់ផ្តើមលះបង់លទ្ធិ-សម្បូរណាញាសិទ្ធិរាជ, ទ្រង់រៀបចំប្រទេសកម្ពុជាឲ្យជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ, ទ្រង់ព្រះរាជទានរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឲ្យប្រជាជនរួមជាតិមានសេរីភាពពេញទី ដូចប្រទេសសេរីទាំងពួងក្នុងសាកលលោក ទ្រង់រៀបចំព្រះរាជរដ្ឋាភិបាលដ៏រៀបរយឲ្យធ្វើការជាប្រយោជន៍ជាតិពិតៗ ។

សព្វថ្ងៃនេះទ្រង់ក្លាហានព្យាយាមបំពេញព្រះរាជបេសកកម្មតាមការឯករាជ្យដ៏សម្បូណ៌ពិតប្រាកដឲ្យខាងតែបាន ដោយសន្តិវិធី ។ ចំណែកក្នុងប្រទេសទ្រង់បានរៀបចំផែនការនានា មានផែនការព្រះស៊ីហនុជាដើម ទ្រង់បង្កើតឲ្យមានកងកម្លាំងហៅថា "កងជីវពល" សម្រាប់ការពារប្រទេសឲ្យបានសន្តិសុខ ឲ្យសមជារដ្ឋឯករាជ្យពិតមែនៗ ប្រវត្តិសាស្ត្រខ្មែរបានគោរពព្រះអង្គជាព្រះមហាវីរៈក្សត្ររដ្ឋបុរសដ៏អង់អាចក្លាហាន ទ្រង់មាន

ប្រសាសនោបាយខាងការចំរើន គឺទ្រង់មានផែនការគ្រប់គ្រងប្រទេស ស្របទៅតាមផែនការនៃព្រះមហាក្សត្រខ្មែរសម័យអង្គរ ឲ្យប្រទេសកម្ពុជារុងរឿងទាំងខាងអាណាចក្រទាំងពុទ្ធចក្រ, គួរឲ្យយើងទាំងឡាយស្ងើចព្រះចេស្តាបារមីនៃព្រះអង្គពន់ពេក នឹងស្រឡាញ់ព្រះអង្គដោយស្មោះ ទាំងបានថ្វាយខ្លួនថ្វាយជីវិតជាពលរដ្ឋដេកក្រោមម្លប់ព្រះរាជសម្ភារបារមី ដោយសេចក្ដីរីករាយជាដរាប ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិ៍ក្នុងលោក សូមប្រសិទ្ធិព្រះពរជ័យពូកែ ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះនរោត្តម-សីហនុ វរ្ម័ន សូមឲ្យប្រទេសកម្ពុជាបានឯករាជ្យសម្បូណ៌ពិតប្រាកដ នឹងបានចំរើនរុងរឿងទាំងខាងអាណាចក្រ ទាំងខាងពុទ្ធចក្រ សមដូចព្រះរាជបំណងកុំខានឡើយ !

## និគមវចនៈ

បទប្រាសាទអង្គរ

ប្រាសាទថ្ម អង្គរខ្មែរ ហៅដេរដាស
បានប្រកាស ពាសពណ៌នា ជាបន្ទាល់
ប្រាប់ជុំវិញ ពេញពិភព លោកសាកល
ឲ្យបានស្គាល់ រាល់ប្រទេស ជាតិនានា ។

ថា "ស្រុកខ្មែរ ឯសម័យ អង្គរវត្ត
ដ៏ប្រាកដ ត្បែកក្នង ចុងបូព៌ា
គឺនៅជ្រោយ សុវណ្ណភូមិ ដ៏សោភា
ដោយរឹទ្ធា ក្សត្រវរ្ម័ន ខ្មែរច្រើនអង្គ ៗ
ដែលទ្រង់សាង ប្រាង្គណ៍ប្រាសាទ ស្អាតសង្ហា
សុទ្ធសិលា ចារិកកត់ ប្រវត្តិវង្ស
តែមហាក្សត្រ នាមវរ្ម័ន និរាសបង់
ទៅយូរលង់ ច្រើនរយឆ្នាំ ច្រើនជំនាន់ ៗ
ទើបផុសបាន មាននាក្នង ក្រុងភ្នំពេញ
នេះឡើងវិញ ចេញព្រះនាម យ៉ាងជាក់ស្បាន
គឺព្រះបាទ សីហនុ វរ្ម័ន
ដ៏សំខាន់ ជាអម្ចាស់ យើងសព្វថ្ងៃ ៗ
ជាប្រផ្ដល ចូលប្រទេស និវេសន៍យើង
ថាត្រូវថ្កើង ឡើងដូចដើម ឆ្ងើមពេកក្រៃ
ទាំងពុទ្ធចក្រ អាណាចក្រ ហាក់រស័យ
ដូចសម័យ នៃអង្គរ បូរាណ ៗ
ដោយព្រះអង្គ ដ៏ទ្រង់ធម៌ បវរនេះ
ទ្រង់បានចេះ ចំណោះឆ្ងើម ផ្ដើមតវ៉ា"

យកឯករាជ្យ　អំណាចពេញ　ឲ្យខេមរា
គឺបេនា　ខ្មែរឲ្យមាន　ជំហានវឌ្ឍន៍ ៗ
ដោយសន្តិ - វិធីល្អ　ដ៏ប្រសើរ
តាមដំណើរ　ដើរប្រពៃ　នៃបណ្ឌិត
ឲ្យជាតិខ្មែរ　ពូកែខ្ពស់　រស់ជីវិត
ថ្កើងសក្តិសិទ្ធិ　ដូចវ៉ន្ម　មុនពុំខាន ៗ
ចេះត្រូវតែ　ខ្មែរស្រីប្រុស　ស្រុះព្រមគ្នា
ក្រោកម៉្មា　លីលាតាម　ស្នាមលំអាន
នៃផែនការ　សីហនុ　ដ៏ចំណាន
ធ្វើទាហាន　ឲ្យបានច្រើន　កើនវឌ្ឍ ៗ
ឲ្យខ្មែរថ្មី　ល្បីដូចចាស់　ជាន់អង្គរ
រឹងជំហរ　ពទឹកដី　កម្ពុជា
អាចតតាំង　ទាំងក្នុង - ក្រៅ　ឥតរញ្ញាក
សមនាមា　ជាឯករាជ្យ　ពិតមែនអើយ !

ជយោកម្ពុជរដ្ឋ !
ជយោព្រះករុណា !

## ពិធីប្រឡងសិស្សសាលាបាលីរង

### នៅដែនកុសាំងស៊ុន ភាគខាងត្បូង

## ព្រះញាណកោសល ញាណ-ឈឹង

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

---

កាលពីថ្ងៃទី ២០ មេសា ឆ្នាំ ១៩៥៣ នៅដែនកូសាំងស៊ុនភាគខាងត្បូង មានសុភមង្គលដ៏ឧត្តមកើតឡើង គឺពិធីប្រឡងសិស្សសាលាបាលីរង ដែលសិក្សាគ្រប់កំណត់វេលា ៣ ឆ្នាំ តាមប្រកាសរដ្ឋមន្ត្រីក្រសួងធម្មការភ្នំពេញ លេខ ២០៥ ថ្ងៃទី ២ កុម្ភៈ ឆ្នាំ ១៩៥៣ និងប្រកាសរដ្ឋមន្ត្រីក្រសួងសិក្សាធិការយៀកណាមនៃព្រៃនគរ លេខ ៧០៩ ថ្ងៃទី ២៩ មករា ឆ្នាំ ១៩៥៣, អនុញ្ញាតឲ្យប្រឡងដោយសួស្តី ៗ មានសមណៈប្រតិភូពីរក្រុម ចេញដំណើរពីភ្នំពេញ គឺមួយក្រុមទៅកាន់ខេត្រឃ្លាំង, មួយក្រុមទៀតទៅកាន់ខេត្រព្រះត្រពាំង ។

### ក) មន្ទីរប្រឡងនៅសាលាបាលីរងវត្តឃ្លាំង ខេត្រឃ្លាំង

មានគណៈកម្មការ ៦ រូប គឺ

១ – ព្រះគ្រូ បញ្ញាវង្ស ថាច់-លន់ ចៅអធិការវត្តឃ្លាំង អធិបតី

២ – ព្រះគ្រូ សេខ-នាង សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ សមាជិក

៣- ព្រះមហា ថាច់-ប៊ុច វត្តឃ្លាំង សមាជិក

៤ - ព្រះមហា ជេន-វង្ស វត្តតាសិក —

៥ - ព្រះមហាឧត្តមវិជ្ជា ថាច់-ស៊ាម វត្តឧណ្ណាលោម —

៦ - ព្រះមហាឧត្តមវិជ្ជៈ លី-ប៊ូរ លេខាធិការ ។

គណៈកម្មការទាំងនេះបានត្រួតត្រាការប្រឡងរួចហើយពិនិត្យឲ្យពិន្ទុតាមចំណេះវិជ្ជារបស់សិស្សនោះៗ តាមលំដាប់ ។

## លទ្ធផលនៃការប្រឡងនៅខែត្រឃ្លាំង

បណ្ដាសិស្សចំនួន ៥១ រូប, សិស្សដែលប្រឡងជាប់ពិន្ទុទុកជាបានការគួរឲ្យសញ្ញាបត្រ មានចំនួនតែ ៣២ រូប ដូចមានពយះឈ្មោះនឹងសំបុត្ររូបថតជូនទុកនៅមន្ទីរពៅក្រសួងសព្វគ្រប់ស្រាប់ ។

## ១) មន្ទីរប្រឡងនៅសាលាគណវត្តពោធិសាលរាជ(កំពង់) ខែត្រព្រះត្រពាំង មានគណៈកម្មការ ៦ រូបគឺ

១ - ព្រះញាណកោសល.ញាណ-ឈឹន ក្រុមជំនុំព្រះត្រៃបិដក អធិបតី

២ - ព្រះមហាឧត្តមវិជ្ជា ថាច់-លឿក វត្តផ្ដោជូង សមាជិក

៣- ព្រះមហាឧត្តមវិជ្ជា វិញ-កឿង វត្តឧណ្ណាលោម -

៤ - ព្រះមហាឧត្តមវិជ្ជា ស៊ឺន-ត វត្តកន្ទុំស្រុក

៥ - ព្រះមហាឧត្តមវិជ្ជា ថាច់ ព្រម វត្តកំពង់ស្ពាន សមាជិក

៦ - ព្រះមហាឧត្តមវិជ្ជា ថាច់ សាប៊ុត វត្តកំពង់ លេខាធិការ ។

គណៈកម្មការទាំងនេះ បានត្រួតត្រាការប្រឡងជាប់តាំងពីម៉ោង ៨ ព្រឹក ថ្ងៃទី ២០ មេសា ឆ្នាំ ១៩៥៣, រួចពិនិត្យឲ្យពិន្ទុតាមចំណេះវិជ្ជារបស់សិស្សតាមលំដាប់ ។

## លទ្ធផលនៃការប្រឡងនៅខេត្តព្រះត្រពាំង

កន្លងណាសិស្សចំនួន ១០៨ រូប, សិស្សដែលប្រឡងជាប់ពិន្ទុកជាបានការគួរឲ្យសញ្ញាប័ត្រមានចំនួនតែ ៧៦ រូប ដូចមានពយនាមនិងសំបុត្ររូបថតទុកនៅមន្ទីរទៅក្រសួងសព្ទគ្រប់ស្រាប់ ។

## ពិធីការមុនប្រឡងនៅខេត្តព្រះត្រពាំង

នៅវេលាម៉ោង ១៨ កន្លះល្ងាច ថ្ងៃ១៩ មេសា ឆ្នាំ១៩៥៣, ព្រះតេជគុណសុវណ្ណប្បញ្ញោ ស៊ិន-ធន់ មេគណខេត្តព្រះត្រពាំង លោកឲ្យប្រជុំអនុគណទាំងទៅអធិការគ្រប់វត្តក្នុងខេត្ត ព្រមទាំងពួកពុទ្ធបរិស័ទប្រុសស្រីឲ្យមកជួបជុំ ហើយលោកបញ្ជាឲ្យអធិបតីមេប្រយោគព្រះនាមញាណ-ឈីន ក្រោកឡើងឈរលើវេទិកាធ្វើប្រស្រ័យទៅកាន់ពុទ្ធបរិស័ទរាប់រយនាក់ ដែលស្រែកឃ្លាននៅរង់ចាំស្តាប់ ដោយពេញសំឡេងឧទ្ទេសនស័ព្វដែលរាជការបៀកណាមឧត្តម ។ ព្រះញាណកោសល ក៏ក្រោកឡើងឈរថ្លែងមាត់ទទេតក្រោងទុកជាមុនអំពីការ

សូមទោស, ជូនស័ព្ទសាធុការពរចំពោះទីប្រជុំ រួចផ្តើមថ្លែងការណ៍សំដៅតែគោលៗ ដូចមានតទៅនេះ ៖

១— អំពីវិធីប្រឡងភាសាបាលីជាគោលសំខាន់នៃលទ្ធិព្រះពុទ្ធសាសនា, ភាសាបាលីមានរបៀបបែបផែនជាលំជ្រៅគម្ពីរភាពក្រៃលែងណាស់ ពុំងាយនឹងសិក្សាត្រឹមរយៈ ៣ ឆ្នាំប៉ុណ្ណោះហើយអាចចេះចាំយកមកប្រឡងបានទេ, ទាំងយោបល់ដ៏ប្រណីតសុំតាមការឲ្យបានប្រឡងភាសានេះ តាមផ្លូវរដ្ឋទាំងពីរជាដំបូងនៅខែត្រព្រះត្រពាំងសោត អស់រយៈវេលា ៦ ខែទើបសម្រេច ។ សភាពទាំងនេះ អាស្រ័យវិរិយពលរបស់សាលាគណ និងពុទ្ធសាសនបណ្ឌិត្យរងនៅមន្ទីរសមាគមខែត្រឃ្លាំង ទំតស៊ូដោយមុឹងមាត់ពុំបណ្តែតបណ្តោយ, ការកម្រៃដែលបានមកប៉ុណ្ណោះ ទុកជាភ័ព្វវាសនាយ៉ាងខ្ពស់ទី ១ ។

២— អំពីសណ្តាប់ធ្នាប់ កិរិយាមារយាទដ៏ថ្លៃថ្នូរនិងសេចក្តីឧស្សាហ៍របស់ព្រះសង្ឃ, ព្រះសង្ឃលុះតែបានសិក្សារៀនព្រះបរិយត្តិឲ្យចេះដឹងជ្រៅជ្រះ ទើបនឹងអាចយល់សេចក្តីថាធ្វើដូច្នេះខុស ដូច្នេះត្រូវ ហើយប្រព្រឹត្តកាន់តាមបែបបទអ្នកបួសដោយទូលំទូលាយសព្វគ្រប់បាន, ក្នុងខនេះទុកជាភ័ព្វវាសនាជាគំរប់ ២ ។

៣— អំពីគុណបំណាច់សមាគមនិងពុទ្ធសាសនបណ្ឌិត្យរងនៅខែត្រឃ្លាំង សមាគមនេះមានលោក ឡឹម-ឯម ជាប្រធាន

មួយអន្ទើដោយសហការរបស់លោក បានផ្តើមឧបត្ថម្ភសិស្សអ្នករៀនទាំងពីរលោកពីរដងមកខ្លួនឈាយបួនឆ្នាំមកហើយ គឺចូតផ្គុំផែនការសព្វចំពូកទៅទល់ទីទឹងផ្ញើដន្នួយអាហាររូបករណ៍ (ប្រាក់ស្បៀងអាហារ) ដល់សិស្សទាំងនោះតាមមាន បង្កើតផលប្រយោជន៍ឲ្យបងប្អូនរួមជាតិអ្នកក្ដសាំងស៊ុនយល់ច្បាស់នៅបច្ចុប្បន្ន, នេះទុកជាកំពូលស្នាក់របស់ ៣ ។

៤— អំពីការទាក់ទងរវាងព្រះសង្ឃគ្រហស្ថពុកពន្ធបរិស័ទ, ១.នេះគឺត្រូវតែរក្សាវិន័យតាមឋានៈរៀងខ្លួន, រីឯខាងព្រះសង្ឃ ត្រូវរក្សាអភិសមាចារិកវត្តមានៈស្លៀកដណ្តប់ត្រៃចីវរ ឲ្យជាបរិមណ្ឌល ប្រព្រឹត្តឥរិយាបថដេក ដើរ ឈរ អង្គុយឲ្យសមរម្យជាដើម, រីឯខាងគ្រហស្ថត្រូវផ្គត់ផ្គង់ដោយបច្ច័យ ៤ តាមកម្លាំងសទ្ធាទឹងជៀស្តាប់ទុកាទ ធ្វើចិត្តស្មោះស្ម័គ្រឲ្យសមតាមគុណរបស់ឧបាសក ត្រង់បទថា សង្គ្រោះ សទ្ធិ សមានសុខទុក្ខ ប៉ុណ្ណោះជាអាទិ៍ សេចក្តីថា "ឧបាសកឧបាសិកាត្រូវរួមសុខទុក្ខជាមួយនឹងព្រះសង្ឃសព្វៗកាល" ដោយពិស្តារទៀតគឺត្រូវដាស់តឿនក្រើនរំលឹកទៅវិញទៅមក ក្នុងវេលាដែលមានហេតុធ្ងន់ធ្ងរ, នេះជាផ្លូវនៃសេចក្តីសាមគ្គីយ៉ាងជ្រាលជ្រៅពិត ជាខសិទានគំរប់ ៤ ។

លុះចប់អត្ថបទទាំង ៤ យ៉ាងខាងលើហើយ ព្រះមហាឧត្តមវិជ្ជា វិញកឿង ក្រោកឈរសូត្រពាក្យប្រកាសអំពាវនាវរបស់សមាគមដដែលនោះ ដើម្បីឃោសនាកសាងមន្ទីរសមាគមឯក្នុងពេញ នៅពេលដ៏ខាង

មុខឯណោះ ។ ពួកពុទ្ធបរិស័ទក៏ប្រគេនសព្ទសាធុការពរថា សាធុ សាធុ ទ្រហឹងអឺងកងឡើងនៅក្រោយរយៈវេលាកន្លងពីរម៉ោង ។

លុះដល់ម៉ោង ៧,៣០ ថ្ងៃ ២ ᧶៦ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦, (២០ មេសា ឆ្នាំ ១៩៥៣) លោក "យ៉ យ៉ាំងដាញ់" ចៅហ្វាយខេត្តព្រះត្រពាំងជាមួយនឹងមន្ត្រីខេត្តជាច្រើន ដែលយើងសូមអភ័យទោសដោយមិនអាចនឹងកត់នាមនឹងលំដាប់ការក្នុងទីនេះ បានអញ្ជើញមកកាន់មន្ទីរប្រឡងនៅវត្តពោធិសាលរាជជាផ្លូវការ ។ គណៈសង្ឃមានព្រះមេគណខេត្តជាដើម នាំគ្នារង់ចាំធ្វើបដិសណ្ឋារៈអញ្ជើញនឹងនិមន្តឡើងកាន់មន្ទីរព្រមគ្នា ។ បន្ទាប់មកព្រះមេគណខេត្តបង្ហាញប្រគណៈសង្ឃថា នេះសមណប្រតិភូដែលរាជការកម្ពុជាចាត់ឲ្យនិមន្តមក, នេះព្រះអនុគណ, នេះចៅអធិការ ។ រួចហើយគណៈសង្ឃសូត្រជយន្តោជូនលោកចៅហ្វាយខេត្តនឹងក្រុមបរិស័ទរបស់លោក ។ តមកទៀតព្រះញាណកោសលតំណាងគណៈសង្ឃធ្វើបាឋកថាមាត់ទទេ ប្រស្រ័យចំពោះលោកប្រមុខខេត្តនឹងមន្ត្រីធំតូចទាំងនោះដោយពាក្យទន់ភ្លន់ថា៖

អាត្មាភាពបានទទួលកិត្តិយសជាអ្នកតំណាងក្នុងនាម នៃពុទ្ធបរិស័ទក្នុងទីប្រជុំនេះ សូមជូនសុវត្ថិមង្គលសួស្ដីដល់អស់លោកដូចមានតទៅនេះ

១- សូមអរគុណយ៉ាងខ្ពស់បំផុតចំពោះដំណើររបស់លោកចៅហ្វាយខេត្តត្រាវិញ នឹងបរិស័ទដែលបានអញ្ជើញមកជាអធិបតីក្នុងពិធីប្រឡងសាលាបាលីរងជាដំបូងនៅទីនេះ ។

២- សូមអរគុណ យ៉ាងវិសេសចំពោះរដ្ឋាភិបាលប្រទេសយៀកណាមនិងរដ្ឋាភិបាលប្រទេសកម្ពុជា ដែលមានសេចក្តីអនុគ្រោះស្របគ្នា ដោយមិត្តភាព បានអនុញ្ញាតឲ្យប្រឡងតាមសុំ ។

៣- សូមទទួលឧបការគុណដ៏ថ្លៃថ្លានេះរបស់ពុទ្ធសាសនបណ្ឌិត្យ រង, សមាគមកូសាំងស៊ីននិងសាលា គណខែត្រព្រះត្រពាំង ដែលអាចឧបត្ថម្ភកល្យាណកិច្ចជាកិច្ចដ៏ធ្ងន់លុបកម្លាំងឲ្យកើតឡើងបាន ដោយឥតមានធុញទ្រាន់ហុចផលប្រយោជន៍ដល់យើងរាល់គ្នា ឧបមាដូចមាតាបង្ហូរទឹកក្សីរចែកឲ្យបុត្រដូច្នោះ អាត្មាភាពទាំងឡាយសូមកត់ចុះក្នុងប្រវត្តិសាស្ត្រទុកថា បម្រុងនឹងធ្វើករណីយកិច្ចស្នងវិញ ក្នុងចម្ងាយជីវភាពត្រឹមណានោះរបស់ខ្លួនៗ តទៅ ។

នៅទីបំផុត អាត្មាភាពទាំងឡាយ សូមបួងសួងប្រសិទ្ធិពរជ័យស័ក្តិសិទ្ធិជូនចំពោះរដ្ឋាភិបាលទាំងពីរឲ្យមានជោគជ័យសព្វទិសានុទិស សូមអសន្តិសុខឃ្លាតឃ្លាតទៅ, សន្តិសុខត្រឡប់វិលចូលមកវិញ ដោយរួសរាន់ទាន់បំណងប្រជាកស្ត្រ, សូមពុទ្ធសាសនបណ្ឌិត្យរង, សមាគមកូសាំងស៊ីន និងសាលាគណខែត្រព្រះត្រពាំង បានតាំងនៅជាសុខសព្វៗកាល ដោយអំណាចគុណព្រះរត្នត្រ័យ កុំបីឃ្លៀងឃ្លាតឡើយ ។

ជយោ ព្រះពុទ្ធសាសនា !

ជយោ ប្រទេសយៀកណាម !

ជយោ ប្រទេសកម្ពុជា !

ជយោ ចៅហ្វាយខេត្តត្រាវិញ !

លុះចប់ហើយ ព្រះមហាឧត្តមវិជ្ជា ថាច់ លៀក ប្រែជាភាសាយៀកណាម ។

តពីនោះមក លោកចៅហ្វាយខេត្តយៀកណាមឡើងឈរលើវេទិកាថ្លែងតបជាភាសាយៀកណាម ដោយប្រសាសន៍ផ្អែមល្ហែមគួរឲ្យប្រតិព័ទ្ធ ទៅកាន់ពុទ្ធបរិស័ទថា៖

សូមពិតពុទ្ធដីកាព្រះករុណាគ្រប់ព្រះអង្គ ! សូមជំរាបលោក-អ្នកទាំងឡាយ ! អំបាញ់មិញខ្ញុំបានស្ដាប់ពុទ្ធដីកាព្រះញាណកោសលអធិបតីសមណប្រតិភូពីភ្នំពេញ លោកបានថ្លែងការណ៍ដោយសេចក្ដីបំប្រួញ លុះជិតនឹងចប់ហើយ លោកចំឡៀតយកឱកាសជំរាបជូនស័ព្ទសាធុការពរចំពោះប្រទេសយៀកណាម, ប្រទេសកម្ពុជា ទាំងខ្លួនខ្ញុំនូវមេត្រីសញ្ញាតិយៀក ណាម-កម្ពុជា ដែលបានអញ្ជើញមកជាមួយ ខ្ញុំមានបីតិសោមនស្សរកតអ្វីនឹងប្រៀបបានឡើយ ។

លោកទាំងឡាយ ! កាលខ្ញុំទើបនឹងមកដល់មន្ទីរសាលាគណភ្នាមក្រឡេកឃើញព្រះសង្ឃច្រើនកុះករធ្វើបដិសណ្ឋារៈជាកិត្តិយសចំពោះខ្ញុំៗរកើបញាប់ញ័រក្នុងចិត្តប្លែកពីធម្មតា, ដោយខ្ញុំពុំបានដឹងពីមុនថាព្រះសង្ឃក្នុងខេត្តនេះរៀនសូត្រភាសាបាលីបានចេះដឹងជ្រៅជ្រះ អាចប្រឡង

យកសញ្ញាប័ត្រ មានប្រមាណដល់ ១០០ ច្បាប់ម្ល៉េះទេ ទឹកស្មានថាលោក ទាំងនោះគ្រាន់តែរៀនបន្តិចបន្តួចត្រឹមតែចេះមើលអក្សរបាលីដាច់ សរសេរតាមសូត្របានតាមរបៀបវត្តប៉ុណ្ណោះឯង លុះឃើញហើយក៏ត្រេកអរត្រិះត្រួចសង្ឃឹមថា ករណីយកិច្ចរបស់ព្រះសង្ឃជាបឋមហេតុវេលានេះនឹងធ្លាក់ជាប់ជាដួរស្នាមដក់នៅក្នុងសន្តានពុទ្ធបរិស័ទមិនថាជាតិណាជាជាតិណាទេ ព្រោះភាសាបាលីនេះជាមូលវិជ្ជាពុទ្ធសាសនាទូលំទូលាយណាស់ ៗ ការប្រឡងវិជ្ជាបាលីនៅខែត្រព្រះត្រពាំងនេះ ជាធម្មសម្បត្តិមួយយ៉ាងពេញលេញសម្រាប់ខែត្រផង, ខ្ញុំសូមប្រគេនពរ សូមឲ្យព្រះករុណាជាបេក្ខសមណៈទាំងឡាយ កើតមានបញ្ញាក្តីស្មានក្នុងបញ្ហាគ្រប់អន្ទើ ដូចពន្លឺព្រះអាទិត្យថ្ងៃត្រង់, សូមគណៈកម្មការសម្រាប់ប្រឡងធ្វើការឲ្យបានផលសមតាមប្រាថ្នា កុំឲ្យមានរអាក់រអួលដរាបដល់ចប់កិច្ចប្រឡង, សូមគណៈសង្ឃក្នុងខែត្របានចម្រើនលូតលាស់ដោយចំណេះវិជ្ជាព្រះពុទ្ធសាសនា គ្រាន់ជាប្រទីបត្រោលបំភ្លឺប្រទេសទាំងពីរឲ្យបានរុងរឿងទៅឯអនាគត ៗ

ជយោ ព្រះពុទ្ធសាសនា!

ជយោ ចៅហ្វាយខែត្រត្រាវិញ!

លុះចប់ហើយលោក ថាច់-យ៉ឺ អធិការបឋមសិក្សាខែត្រត្រាវិញ ប៉ែកខាងខ្មែរប្រែជាកម្ពុជភាសា ៗ

លុះស្ងប់សំឡេងឱ្យសាធុការពររួចហើយ ទើបលោកអធិបតីខែត្រព្រះត្រពាំងប្រគេនវិញ្ញាសាប្រឡងទៅគណៈកម្មការ ហើយលាត្រឡប់ទៅវិញ ។ មុននឹងត្រឡប់ អ្នកចាត់ការសម្រាប់គណសូមថតបរិស័ទទាំងអស់, ប៉ែកខាងព្រះសង្ឃមានលោកគ្រូមេគណវត្តពោធិសាលកជាដើម, ប៉ែកខាងគ្រហស្ថមានលោកចៅហ្វាយខែត្រយៀកណាមជាប្រធានទុកជាអនុស្សាវរីយ៍ ។

លំដាប់តពីនោះមក គណៈកម្មការប្រឡងតាំងផ្ដើមបើកវិញ្ញាសាដែលមានស្រោមបិទកាកល័ខ បង្ហាញនិស្សិតទាំងនោះចំពោះមុខ ។ មេប្រយោគនឹងសិស្ស ក៏ប្រតិបត្តិវិធីប្រឡងតាមកម្មវិធីទាំងពេលព្រឹកល្ងាចដរាបដល់រួចកិច្ច ដូចមានសេចក្តីកត់ហេតុសព្វគ្រប់ស្រាប់ ។

## ទំរង់ការក្រោយប្រឡង

លុះដល់ថ្ងៃ ៥ ១១ ៦ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ (២៣ មេសា ឆ្នាំ ១៩៥៣) ក្រោយថ្ងៃប្រឡងសរសេររួច វេលាម៉ោង ៩ ព្រឹក មានការប្រជុំសម្រាប់គណត្រង់មន្ទីរដដែល ។ ខណៈនោះព្រះមហាថេរជាមេគណ អនុគណ ចៅអធិការវត្តសម្រោងព្រះនាម គង់ ជាព្រះថេរៈចាស់ទុំ ព្រមទាំងមន្ត្រីឃុំ-ស្រុក អាចារ្យវត្តផ្សេងៗ ក្នុងខែត្របានមកកាន់ទីប្រជុំតាមលិខិតនិមន្តអញ្ជើញរបស់សាលាគណចុះថ្ងៃទី ១៩ មេសា ឆ្នាំ ១៩៥៣ ដើម្បីស្ដាប់សន្និសិទក្នុងសំណាក់ព្រះតេជ-គុណព្រះញាណកោសល ។

កាលនោះ ព្រះថេរៈអង្គនេះ ថ្លែងការប្រស្រ័យទៅកាន់បរិស័ទ សំដៅយកតែគោលសំខាន់ៗ មាន៤មាត្រា តាំងអំពីវិធីប្រឡងភាសាបាលីជាដើមដរាបដល់មាត្រាជាគំរប់ ៤ ផ្សេងដោយអធិប្បាយខ្លះ ប្រ-ហែលគ្នានឹងអត្ថបទក្នុងថ្ងៃទី ១៩ មេសា ខាងលើខ្លះ; លុះចប់ហើយទើបព្រះមហាវិញ-គឿងប្រកាសសេចក្ដីអំពាវនាវរបស់សមាគមដូចមុន ៗ បញ្ចប់ការធ្វើប្រស្រ័យនោះនៅម៉ោង ១១ ។

លុះដល់ថ្ងៃ ១ ៤ ៗ ៦ ឆ្នាំម្សាញ់ (ទី ២៦ មេសា ឆ្នាំ ១៩៥៣) ម៉ោង ១៥ រសៀល មានរថយន្តរ៉ឺសេសមួយតូចយ៉ាងស្អាតជាបេសកកម្មរបស់ព្រះតេជព្រះគុណ សឹង វ៉ិន វិសុទ្ធិបញ្ញោ ចៅអធិការវត្តចេកជ្រំ អនុគណស្រុកបណ្ដា ខេត្រត្រាវិញ ឲ្យមកទទួលព្រះមេគណខេត្រនិងសមណៈប្រតិភូពីភ្នំពេញដើម្បីទៅទស្សនាការមន្ទីរអនុគណ, សាលាបឋមសិក្សាបាកំង-ខ្មែរកងឃុំហ៊ុបក៏ ស្រុកបណ្ដានោះ ដែលនៅខាងត្បូងសាលាខេត្រ ប្រហែល ៣០ គ.ម. អំពីសាលាខេត្រ ។ លុះរថយន្តជិតនឹងដល់ ស្រាប់តែឃើញទង់ជ័យ៣ប្រភេទគឺទង់ យៀកណាម, ទង់ប្រាសាទ ទង់ព្រះពុទ្ធសាសនា លើកឡើងប្រង់ប្រាងនៅសងខាងផ្លូវដែលមានបម្ងាយ ១ គ.ម. ទីងដល់ទីនោះ ៗ បន្តិចទៀត ឮស្គរសំឡេងស្គរធំ-ដូង រគាំង បន្ទឺឡើងយ៉ាងអឹកធឹកកងរំពងទទួលជាកិត្តិយសចំពោះព្រះមេគណខេត្រ ព្រះមហាថេរជាអធិបតីខេត្រ ព្រមទាំងសមណប្រតិភូ

ដែលរៀបដំណើរចុះពីលើរថយន្ត ៗ វេលានោះគណៈកម្មការអនុគណ បេកជ្រំដែលមានព្រះមហាឧត្តមវិជ្ជា យុត - យ៉ឺន ជានាយបញ្ជាការ បាន ឲ្យពួកព្រះសង្ឃមានឋានៈជាឧបជ្ឈាយ៍ ចៅអធិការនិងសិស្សសាលា បាលីរងចាំទទួលដំណើរ បន្ទាប់មកឧបាសក-សិកា តទៅទៀត កូនសិស្សសាលាបឋមសិក្សា មានចំនួនប្រហែល ២០០ នាក់រួមទាំង កុមារកុមារីកាន់ទង់ជាតិ, ទង់សាសនាឈរអមទាំងខាងឆ្វេង - ស្ដាំ តាម សេចក្ដីបញ្ជារបស់លោកគ្រូ - អ្នកគ្រូសាលានោះ ៗ លំដាប់នោះ ព្រះ មហា យុត-យ៉ឺន អាចារ្យសាលាបាលីរងវត្តបេកជ្រំ នាំមុខព្រះសង្ឃសូត្រ ជយមង្គលប្រគេនពរស្វាគមន៍ ហើយនាំចូលទៅកាន់សាលាបាលីរងថ្មី, មន្ទីរសាលាអនុគណបណ្ដោះអាសន្នផង, លុះព្រះសង្ឃនឹងគ្រហស្ថនៅ ទីនោះស្ងប់ស្ងៀមហើយ ទើបព្រះមហា យុត - យ៉ឺន តំណាងអនុគណ ក្រោកឈរសូត្រពាក្យទទួលអំណរ ៗ បន្ទាប់មក អាចារ្យស្រមាប់វត្ត នោះតំណាងប៉ែកខាងគ្រហស្ថសូត្រពាក្យទទួលអំណរ ៗ លុះចប់ហើយ ព្រះមហាមឿង - សាន ហៅម៉ុក ( សុវណ្ណប្បញ្ញោ ) អាចារ្យសាលា បាលីរងវត្តពោធិសាលរាជ តំណាងព្រះមេគណតបវិញដោយថេរដីកា ដ៏ជ្រាលជ្រៅ ព្រមទាំងពោលដាស់តឿនក្រើនរំលឹកកិច្ចការខាងគណឲ្យ ខំធ្វើសេចក្ដីប្រតិបត្តិ, រៀនសូត្រ, តាំងសាលាបាលី, សាលាធម្មវិន័យ ឲ្យមានគ្រប់វត្ត ដើម្បីឲ្យកុលបុត្របានចូលរៀនដោយងាយ ទើបពុទ្ធ-

សាសនាក្នុងខេត្តនេះនឹងចំរើនរុងរឿងទៅបាន ។ តពីតំណាងព្រះមេគណមក លោកគ្រូចៅអធិការវត្តចេកជ្រំ សូមអារាធនានិមន្តព្រះញាណកោសលឲ្យថ្លែងការណ៍ដ៏ថ្លៃក ៗ ដែលទើបនឹងកើតឡើងជាដំបូងក្នុងខេត្តនេះ ចែកជូនពុទ្ធបរិស័ទដែលមិនបានទៅកាន់ទីប្រជុំឲ្យបានស្តាប់ផង ។ លោកអធិបតីប្រតិភូក៏ថ្លែងសារស័ព្ទរឿងហេតុផ្សេងៗ តាមដំណើរការដូចកាលសំដែងនៅខេត្តក្នុងថ្ងៃ ១៩ មេសា ១៩៥៣ ដែរ គឺរៀបរាប់អំពីផលនៃការប្រឡងភាសាបាលីគ្រាបច្ចុប្បន្នជាដើម មិនប្លែកគ្នាអំពីការដេញប្រះបោគកាល់ក្នុងឆ្នាំ ១៩១៣ ក្នុងវិហារព្រះកែវមរកតឯក្នុងពេញជាន់នោះទេ ផ្សេងតែប្រើបាលីមាត់ទទេចំពោះមុខមេប្រយោគប៉ុណ្ណោះ ៗ មុននឹងបញ្ចប់ លោកជៀតឱកាសអង្វាកទៅរកព្រះសង្ឃទាំងពួង ប្រគេនឱវាទថា សូមព្រះករុណាទាំងឡាយកុំស្និទ្ធស្នាលនឹងការដើរមើលផ្សារគួចធំពេក លុះណាតែមានការខានពុំបានសិមទៅ សូម្បីដូច្នោះ ក៏ត្រូវតែមានឧបាសកជាវេយ្យាវច្ចជង់ទើបគួរ សូមទឹកដល់ទីកន្លែងពុំគួរគ្រាប់កុំភ្លេចឲ្យសោះ ដើម្បីរក្សាដម្លៃព្រះពុទ្ធសាសនាកុំឲ្យសាបរលាបដោយសារតែយើងកាល់រូបឡើយ ៗ លុះចប់កិច្ចការប្រស្រ័យ-តបតហើយ ព្រះមហាវិញ-កឿង ក្រោកឡើងអានសេចក្តីអំពាវនាវរបស់សមាគមដូចមុនៗទៀត ។ បញ្ចប់ការជំរើបជ័សណ្ឋារៈនៅម៉ោង ៥, គណៈកម្មការទាំងអស់ត្រឡប់វិលមកវត្តពោធិសាលពដវិញ ៗ

លុះដល់ម៉ោង ១៩ រសៀលថ្ងៃ ៥ ៗ៣ ៦ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ (៣០ មេសា ឆ្នាំ ១៩៥៣) ក្រោយថ្ងៃដែលពិនិត្យវិញ្ញាសាប្រឡងរបស់សិស្សបានដឹងជាជាប់លេខមានប៉ុន្មាន, ធ្លាក់អស់ប៉ុន្មានរួចហើយ មានការប្រជុំសូត្រហៅឈ្មោះសិស្សដែលជាប់ពិន្ទុមកប្រគេនព្រហ្មទានតាំងពីលេខ ១ ដល់ ៧២ តាមលំដាប់ ៗ មុនទីងប្រគេនព្រហ្មទាន លោកអធិបតីមេប្រយោគឲ្យឱវាទថា សូមសិស្សទាំងឡាយកុំភ័ន្តគំនិតយល់ថា: ការប្រឡង ចេញពីសាលាបាលីរងនេះ សិស្សតែងបានវង្វាន់ដូច្នេះពុំមែនទេ វង្វាន់ពេលនេះកើតដោយសទ្ធាព្រះមេ-គណនឹងគណៈកម្មការរបស់លោក ៗ សិស្សប្រឡងជាប់ ត្រូវបានតែសញ្ញាប័ត្រ ១ សន្លឹកប៉ុណ្ណោះឯង សញ្ញាប័ត្រនោះសោត បើធ្លាក់សាលារង ត្រូវមានសិទ្ធិចូលទៅប្រឡងដណ្ដើមកន្លែងរៀននៅសាលាបាលីជាន់ខ្ពស់ ឬប្រើការងារទៅបានខ្លះ បែកខាងពុទ្ធសាសនាតាមសមគួរ, សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ត្រូវមានសិទ្ធិចូលទូលាយជាងនេះជាទ្វេគុណ ព្រោះហេតុនោះ ត្រូវលោកទាំងឡាយខំព្យាយាមបន្តវិជ្ជាឲ្យបានចេះដឹងច្រើនឡើងទៀត កុំអាលបន្ធូរបន្ថយសោយតាកព្យាយាមឡើយ ដ្បិតប្រទេសជាតិមាតុភូមិនឹងសាសនា នៅរង់ទន្ទឹងចាំអស់លោកទាំងឡាយ សង្ឃឹមថាលោកនឹងជួយជ្រោងឲ្យខ្ពង់ខ្ពស់អណ្ដែត

ត្រៃសតឡើងបានទៅឯអនាគត ។ ខ្ញុំសូមប្រគេនពរស័ព្ទសាធុការ ឲ្យបានចំរុងចំរើនសព្វៗ កាលកុំបីឃ្លាតឡើយ ។

បន្ទាប់អំពីនោះមកទៀត ព្រះមេគណ រូបហើយលោកចៅអធិការ ញោមវត្ត អាចារ្យសម្រាប់វត្តពោធិសាលពជឲ្យស័ព្ទសាធុការពរបន្ត ។ លុះចប់ហើយ ទើបនិស្សិតទាំងនោះសូត្រទទួលគបដោយសេចក្ដីពោះ ក្បោះក្បាយគួរឲ្យចាប់ចិត្តជាកិរិយាភាព ។

ពិធីប្រគេនព្រហ្មទានចប់នៅម៉ោង ១៨ថ្ងៃ ៣០ មេសាឆ្នាំ ១៩៥៣ ។

អ្នកនិពន្ធ

ព្រះញាណកោសល

ញាណ - ឈឹន